# សុភាសិតខ្លី

www.elibraryofcambodia.org

គំនិតដល់មិត្តអ្នកអានពិចារណា ។

ក្នុងការបោះពុម្ពផ្សាយលើកទី ២ នេះ អ្នកនិពន្ធបានប្តូរគ្រប សៀវភៅខាងមុខថ្មីតាមសម័យនិយម និងបានស្រាវជ្រាវបន្ថែម ច្រើនចំនួនរយគំនិតថ្មីៗថែមទៀត ដើម្បីមិត្តអ្នកអានពិចារណា ។

ព្រែកលួងថ្ងៃ ៣០-៦-៧២

អ្នករៀបរៀង

ហ៊ីន គីមសា៊

www.elibraryofcambodia.org

# ខ្ទរជៅ

● មិនអាចស្រឡាញ់មនុស្សពីរនាក់ឲ្យស្មើគ្នាបានទេ ។

● វត្ថុបំណងនឹងចិត្តគំនិតរបស់មនុស្សយើង វាមានការប្រែប្រួលច្រើនណាស់ អនុលោមទៅតាមអាយុ នឹងលក្ខណៈនៃការរស់នៅ ។

● គ្មានមនុស្សណាអាចធ្វើការធំដុំបានទេ បើប្រាសចាកនូវសេចក្ដីព្យាយាមប្រឹងប្រែងយូរអង្វែង ។

● បើយើងយល់ថា : ការនិយាយច្រើននាំឲ្យខ្លួនថោក ហើយគេមិនចូលចិត្ត យើងគប្បីនៅស្ងៀមបន្ថយការនិយាយច្រើន តែគេមិនឲ្យយើងធ្វើគទេ ។

● មិនត្រូវបណ្ដោយខ្លួនឲ្យប្រែប្រួលទៅតាមការរស់នៅនៃមនោសញ្ចេតនាឡើយ ត្រូវខំប្រឹងធ្វើម្ចាស់ខ្លួនឲ្យបានគ្រប់លក្ខណៈនឹងកាលៈទេសៈ ។

● កុំគប្បី គ្មានអ្វីមិនដឹងហើយមិននិយាយ , គ្មានអ្វីមិននិយាយហើយមិននិយាយឲ្យអស់ ។

www.elibraryofcambodia.org

● ត្រូវយល់ថា ៖ មនុស្សពូកែនិយាយ មិនអាចធ្វើការពិតឲ្យទៅជាមិនពិតបានឡើយ ពីព្រោះទឹកទន្លេគេមិនអាចកួរដោយបាយម៉ានដរាបណាគ្មានមេឡាំ ។

● មិនត្រូវប្រើមនុស្សឲ្យធ្វើការអ្វីក្នុងពេល ដែលគេមិនទាន់ចង់ត្រូវធ្វើឲ្យគេចង់សិនសឹមប្រើ ។

● ការចេះប្រើសំដីនឹងចេះថ្លឹងសំដី គឺជាបច្ចេកទេសនៃស្នេហ៍មុខ ។

● វត្ថុៈ ដែលមានតម្លៃក្នុងលោកគឺ ៖ ការដែលនិយាយនឹងអកប្បកិរិយា ឬកពារដើរស្របគ្នា ។

● ស្រឡាញ់ , ផឹកទឹកទន្លេក៏ផ្អែម , បើស្អប់ស៊ីអំពៅក៏ជូរ ។

● គេអាចយល់បានថា ជាងពូកែនៅក្នុងការងារធ្វើ ។

● គេស្គាល់មិត្តល្អនៅក្នុងគ្រាក្រ ។

● សត្វត្រចៀកកម្មមួយ មិនអាចធ្វើជារដូវរំហើយ បានឡើយ ។

● អត់ទ្រាំ . . . អត់ទ្រាំ . . . នឹងចេះអត់ទ្រាំ គឺជាមធ្យោបាយទៅដល់ជ័យជំនះ ។

www.elibraryofcambodia.org

● បើគ្មានអាទិទេព ជីវិតរបស់មនុស្សនឹងក្លាយទៅជាគ្មានន័យ ពីព្រោះមនុស្សចូលចិត្តដើរតាមចនោសញ្ចេតនា ។

● កាលណាយើងចេះព្យាយាម មានចិត្តស្វាហាប់ យើងត្រូវយល់ថាជីវិតយើងនឹងបានថ្ងៃថ្នូរ ។

● បើយើងចេះអនុវត្តតាមពាក្យសំដី ដែលយើងទូន្មានគេឲ្យប្រព្រឹត្តនោះ មនុស្សយើងនឹងទៅជាទេវតាទាំងអស់ ។

● រាល់ព្រឹក មុននឹងលុបលាងមុខ មិត្តភក្តិបានហាត់ចិត្តឲ្យធ្លាប់ : «ថ្ងៃនេះខ្ញុំមិននិយាយច្រើន ថ្ងៃនេះខ្ញុំនិយាយឲ្យពិរោះហើយត្រឹមត្រូវ » ។

● ធម្មតា មនុស្សយើងទំរាំតែដឹងខុស ថាខុសជ្រុលទៅហើយ មានតែប្រការសំខាន់មួយ គឺចេះយកកំហុសនោះមកធ្វើជាមេរៀនទេ ។

● មានឧបសគ្គ មករាំងរាមិត្ត ហេតុអ្វីក៏មិត្តភ័យហើយស្ងន់, ហេតុម្តេចក៏មិនប្រឹងប្រែង អត់ធន់ ពុះពារទម្លាយឧបសគ្គនោះទៅ ។

● ការត្អូញត្អែរគឺជាការបរបោសអង្អែលមួយ ចំពោះមនុស្សដែលមានការឈឺចាប់ ។

www.elibraryofcambodia.org

● យើងមិនគ្រាន់តែចៀសវាងនូវអំពើអាក្រក់ ដែលសង្គមមនុស្សគេថាអាក្រក់នោះទេ សូម្បីតែយើងថាអាក្រក់ក៏ត្រូវចៀសវាងដែរ ។

● មិនត្រូវដាក់ខ្លួនឲ្យថោកទាប ពីព្រោះតែការស៊ី ការផឹក។

● កិច្ចការសំខាន់របស់ជីវិតមនុស្ស គឺស្វាប់រស់ដោយសារឧត្តមគតិមួយ នឹងជ័យជំនះជាចុងក្រោយមួយ ។

● នៅក្នុងវិស័ យសិល្បៈ គេត្រូវចាប់ផ្ដើមពីបរិមាណទៅគុណភាព ។

● ស្រឡាញ់មនុស្សម្នាក់ ត្រូវគិតដល់មនុស្សនោះ ជួយមនុស្សនោះឲ្យមានសុភមង្គល ថាស្រឡាញ់មនុស្សម្នាក់ បើមិនគិតដល់មនុស្សនោះទេ គឺស្រឡាញ់បោកប្រាស់ ។

● នៅក្នុងពេលអនុវត្តកិច្ចការអ្វីមួយ យើងត្រូវគិតថាខ្លួនយើងមានសត្រូវច្រើនជាងមិត្ត ។

● នៅក្នុងជីវិតមនុស្ស បើចិត្តយើងស្រោលពេក ប្រាកដជាយើងមិនសូវមានមិត្តភក្រច្រើន ហើយមិនសូវបានសប្បាយផង ។

● គប្បីនិយាយឲ្យតិចតែធ្វើការឲ្យច្រើន មិត្តនឹងបានគេ

www.elibraryofcambodia.org

គោរព ហើយគេកោតសរសើរជាមិនខាន ។

● មនុស្សយើងអាចមានចិត្តសប្បុរសណាស់ , ចេះដឹងណាស់ ប៉ុន្តែនៅល្ងាភស៊ីក៏ណាស់ដែរ ។

● ដើម្បីពង្រីកការរាប់អានឲ្យបានងាយ យើងត្រូវចេះនិយាយឲ្យពិរោះ ត្រូវចេះស្តាប់គេនិយាយ ត្រូវចេះសរសើរជាងទិះទៀន ហើយមិនត្រូវនិយាយអំពីរឿងរបស់ខ្លួនឲ្យគេស្តាប់ច្រើនពេកទេ ។

● កាលណាខ្លួនធ្វើធំ ចញ្ជាកិច្ចការធំ បើចង់បានជ័យជំនះហើយឲ្យគេចូលចិត្ត មិត្តត្រូវជៀវាសនា ត្រូវនឹងន ត្រូវពិចារណាត្រូវរាក់ទាក់រាបសារ ត្រូវប្រុងប្រយ័ត្ន អត់ធ្មត់និងរួសរាយ ។

● នៅក្នុងកន្លែងថ្មីណាមួយ ដែលខ្លួនទើបនឹងស្គាល់ គេមិនត្រូវរិះគន់នូវប្រការណាដែលទាស់នឹងគំនិតយើង ហើយក៏មិនត្រូវប្រញាប់ប្រញាល់ជឿគេពេកដែរ ក្នុងកិច្ចការរកស៊ីធំដុំ ។

● ក្នុងការនិយាយទាក់ទងត្រូវរួសរាយ , រាក់ទាក់រក្សាសភាពនឹងន , ហើយស៊ុជព្រៅ ។

● ធ្វើកិច្ចការអ្វី ត្រូវហ៊ានទទួលខុសត្រូវហើយទ្រាំលំបាក

www.elibraryofcambodia.org

អនុវត្តឲ្យបានល្អ ។

● ធ្វើការអ្វីមួយ បើខ្វាចពាក្យទិះទៀនពីអ្នកដទៃ ការនោះពិតជាមិនបានល្អ ហើយមិនបានសម្រេចឡើយ ។

● ចង់បានសហការីល្អ មុនដំបូងគេមិនត្រូវបង្ហាញវត្ថុចំណាងរបស់ខ្លួនឡើយ គេត្រូវរាប់អានស្និទ្ធស្នាលនឹងមនុស្សនោះ, បង្កើតការរាក់ទាក់ . . . គេត្រូវរើសឱកាសល្អ ដើម្បីពីគ្រោះនឹងមនុស្សនោះទើបបានសម្រេច ។

● មនុស្សមិនមែនអាក្រក់ទេ ប៉ុន្តែមិត្តកុំជឿមនុស្សទាំងអស់ពេក ។

● រាប់អានមនុស្សម្នាក់ៗត្រូវឲ្យស្មោះត្រង់, ប៉ុន្តែកុំប្រាសចាកបញ្ញា ។

● រាល់ថ្ងៃយើងច្រើនពិភាក្សាជាមួយមនុស្ស ដែលយើងស្គាល់ ប៉ុន្តែយើងកុំភ្លេចថា មានមនុស្ស ដែលយើងមិនស្គាល់ច្រើនគ្នា គេអាចផ្តល់យោបល់ល្អឲ្យយើង ។

● បើយើងស្រឡាញ់ព្រះ ហើយស្រឡាញ់ខ្លាំង សេចក្តីស្លាប់របស់យើងមិនទៅជាការធំដុំទេ ។

www.elibraryofcambodia.org

● ស្នេហារបស់ប្រុសសម្រាប់បន្តពូជ តែស្នេហារបស់ស្រីសម្រាប់ពលិកម្ម ។

● ក្នុងមួយថ្ងៃៗ បើយើងធ្វើកិច្ចការតូចណាមួយសម្រាប់ឧត្តមគតិយើង ក្នុងអានាគត យើងបានលទ្ធផលមួយយ៉ាងធំ ។

● បើយើងឮថាមិត្តសហភាតរៈ របស់យើងម្នាក់ ធ្វើការបានជ័យជំនះល្អជាងយើង, ហើយខ្លួនយើងនៅធម្មតា នោះគឺយើងមានធម៌មេត្តាខ្ពង់ខ្ពស់ហើយ ។

● សប្បាយខ្លាំងចំពោះខ្លួនប្រាណ នោះគឺមនុស្សប្រុសមានស្រី ប៉ុន្តែសប្បាយចំពោះខួរក្បាលនឹងចំពោះផងប៉ាកា គឺការធ្វើនយោបាយ វាសប្បាយជាង ។

● ធ្វើធំត្រូវចេះអត់ធ្មត់រឿងតូចៗ ដើម្បីយករឿងធំៗ ។

● មានពេលខ្លះ ពីព្រោះតែចង់ឲ្យគេសសើរ ចង់ឲ្យគេស្រឡាញ់ ទៅជាប្រើពាក្យសំដីនឹងឫកពារថោកទាបចំនុតទៅវិញ ។

● ក្នុងពេលដែលគេគ្មានប្រការអ្វីណាដើម្បីស្រឡាញ់ គេត្រូវស្រឡាញ់ប្រការដែលគេកំពុងមាន ។

www.elibraryofcambodia.org

● នៅកន្លែងណាខ្វះសមគាត នៅកន្លែងនោះគ្មានមិត្តភាពទេ ។

● ឫសគល់នៃមិត្តភាពគឺការយល់គ្នា ។

● មិនអាចស្រឡាញ់ជាលើកទីពីរបានទេ ចំពោះមនុស្សណាដែលយើងបានដាច់ស្រាច់ឈប់ស្រឡាញ់ហើយ ។

● កំពុងតែស្រឡាញ់គ្នា មនុស្សមិនសូវគិតដល់រឿងបែកគ្នាទេ នេះបានចំជាប្រហែស ។

● នៅក្នុងរឿងប្រចណ្ឌដែលនាំឲ្យខឹងទៅជាស្អប់ វាកើតឡើងពីស្រឡាញ់ ។

● ក្នុងករណីដែលគេយល់ យើងច្រឡំឬគេចោទថាយើងអាក្រក់ យើងត្រូវខាំមាត់ហើយព្យាយាមធ្វើអំពើល្អ ឲ្យគេយល់បានទោះនាប់ឬយូរក៏ដោយ ។

● ក្នុងការរស់នៅរបស់មិត្តរាល់ថ្ងៃ មិត្តត្រូវទុកពេលខ្លះសម្រាប់ពិនិត្យមើលសំដីនិយាយ , ចិត្តគំនិតនឹងអាកប្បកិរិយាក្នុងថ្ងៃនោះ ។

● ទឹកមុខត្រូវរក្សាឲ្យធម្មតា, ត្រូវចេះញញឹមច្រើមប្រើយ៍ជានិច្ច

www.elibraryofcambodia.org

ទោះក្នុងកាលៈទេសៈណាក៏ដោយ ។

● ពាក្យផ្អែមល្ហែមមិនមែនជាគ្រាប់ស្ករ សម្រាប់មនុស្ស ប៉ុន្តែពាក្យផ្ទូរចត់វាជាឱសថយ៉ាងសំខាន់ ។

● មានគ្រោះថ្នាក់ពីរធំៗគឺ ការនិយាយច្រើន នឹងមានកាយគុណច្រើន បើយើងធ្វើម្ចាស់វាបានគឺយើងជាមនុស្សក្លាហាន ហើយអាចក្លាយទៅជាវីរបុរសផង ។

● មិត្តត្រូវខំប្រឹង ធ្វើឲ្យខួរក្បាលយើងសប្បាយរីករាយជានិច្ច បង្ហាញនូវការរស់រាយចំពោះការរាប់អាននឹងមនុស្សដទៃ ។

● ក្នុងពេលឈឺចាប់មកអំពីបែកបាក់គ្នា ឬដោយប្រការណាមួយ បើយើងចង់ឲ្យបានធូរស្រាលជាធម្មតាវិញ គប្បីយល់ថា : ព្រះជាម្ចាស់ឬអាទិទេពជាជំរកនៃមនុស្សឈឺចាប់ ។

● បេះដូងរបស់យើង យើងអាចបញ្ឆោតវាបាន ប៉ុន្តែជាការងាយបំផុតទៅទៀត គេអាចបញ្ឆោតបេះដូងអ្នកដទៃបាន កាលណាគេចេះ ។ ជាការលំបាកបំផុតបញ្ឆោតបេះដូងខ្លួនឯងកាលណាយើងមិនចេះ ។

● ក្នុងការរស់នៅយើងចេះតែខំប្រឹងស្មោះត្រង់ ធ្វើការធម្មតា

www.elibraryofcambodia.org

ចេះយកចិត្តគេ , និយាយត្រឹមត្រូវ . . . មិត្តត្រូវជឿថា មាន មនុស្សច្រើនគ្នាគេល្អចស្រឡាញ់មិត្ត ល្អចជួយមិត្តជាមិនខាន ។

● បើមាននរណាសួរថា នៅក្នុងលោកមានសេចក្ដីស្នេហា ណាដែលខ្ពង់ខ្ពស់, ស្អាតបាត បរិសុទ្ធ ទូលំទូលាយនឹងយូរ អង្វែងជាងគេ ខ្ញុំហ៊ានឆ្លើយថា : គឺសេចក្ដីស្នេហារវាងម្ដាយហើយ នឹងកូន ។

● កុំបណ្ដោយឲ្យគំនិតធុញទ្រាន់ , ការខ្ជិលរស់រាយមកអុក ឡុកក្នុងខួរក្បាលយើងឲ្យសោះ ។

● ក្នុងជីវិតមនុស្សគ្មានអ្វីមានតម្លៃសោះ វាមានតម្លៃក៏ព្រោះតែមនុស្សដែរ ។

● ចង់មិនសុទ្ធតែបាន ប៉ុន្តែមានពេលខ្លះមិនបាន ព្រោះ យើងមិនចង់ ។

● មនុស្សមានយោបល់ទើបនិយាយចេញ ប៉ុន្តែមនុស្ស នៅស្ងៀមក៏មិនមែនឥតប្រយោជន៍ដែរ ។

● យើងគប្បីប្រើពាក្យសំដីនឹងស្វាបប៉ាការ បំរើយុត្តិធម៌ បំរើជាតិនឹងបំរើខ្លួន ។

www.elibraryofcambodia.org

● កាលណាខ្លួនធ្លាក់ក្រ ត្រូវមើលអ្នកក្រជាងខ្លួន កាលណាខ្លួនមាន ត្រូវងើយមើលអ្នកមានជាងខ្លួននោះ ទើបបានល្អប្រសើរ។

● ក្នុងពេលសរសេរឬនិយាយ មិត្តត្រូវពិចារណាឲ្យជ្រៅជ្រះ ចង់បានជ្រៅជ្រះត្រូវចេះថ្លឹងចេះវាស់ពាក្យសំដីណាដែលខុសត្រូវ ខាត ចំណេញ ជិត ឆ្ងាយ ។

● ជាការល្អយ៉ាងដែរ កុំទិះទៀនអ្នកណាឲ្យសោះ មិត្តចេះតែខំធ្វើការ ដើម្បីកសាងសង្គមមនុស្សឲ្យបានល្អ ដែលមិត្តចង់ទិះទៀននោះទៅ ។

● ចង់រស់នៅរាល់ថ្ងៃឲ្យបានគ្រប់ ២៤ ម៉ោង មិត្តត្រូវមានឧត្តមគតិថ្ងៃថ្នូរ មានកម្មវិធីប្រតិបត្តិការ មានសុខភាពហើយនឹងសតិអារម្មណ៍ល្អជានិច្ច ។

● នៅក្នុងសង្គមមនុស្ស មានមនុស្សរៀនសូត្រខ្ពង់ខ្ពស់ល្បីល្បាញខាងវិទ្យាសាស្ត្រច្រើន ប៉ុន្តែនៅក្នុងខួរក្បាលគេមានគំនិតរបិញ របុញក៏ច្រើនណាស់ដែរ ។

● ត្រូវទម្លាប់ឲ្យមានគំនិត ច្បាស់លាស់ក្នុងការអធិប្បាយបញ្ចេញសតិអារម្មណ៍របស់ខ្លួន ត្រូវអធិប្បាយឲ្យដាច់ស្រាច់ ច្បាស់

www.elibraryofcambodia.org

លាស់ ចៀសវាងកុំនិយាយស្រពិចស្រពិល ។

● ទៅណាមកណា បើមិនចេះធ្វើឲ្យគេស្រឡាញ់ទេ កុំតែធ្វើឲ្យគេស្អប់ វាប្រសើរណាស់ហើយ ។

● បើមិត្តមិនចេះធ្វើខ្លួនឲ្យទៅជាព្រះអាទិត្យ ដើម្បីបំភ្លឺលោកហេតុអ្វីក៏មិនព្រមធ្វើខ្លួនឲ្យទៅជាចង្កៀង ដើម្បីបំភ្លឺអ្នកជិតខាងផង ។

● សេចក្តីវេទនាដែលកើតឡើងដោយឮគេនិយាយ វាមិនស្មើនឹងវេទនាពិតប្រាកដទេ ។

● ចំពោះមនុស្សម្នាក់ៗ វាមានការល្អច្រើនជាងការអាក្រក់ យើងត្រូវមើលឃើញការល្អរបស់គ្នាផង ដើម្បីឲ្យអន់ស្អប់គ្នា ។

● មិត្តគប្បីកុំនិយាយ អាក្រក់ឬចំអកឡកឡឺយ ឲ្យមនុស្សអាក្រក់ មនុស្សចំអក , មិត្តនឹងបានឈ្នះ មនុស្សអស់នោះ ។

● ត្រូវទម្លាប់ស្រាយរាក់ទាក់ ឲ្យដូចសត្វឆ្កែ តែត្រូវស្ងៀមស្ងាត់ឲ្យដូចសត្វគោ ។

● ក្នុងការរស់នៅ យើងគប្បីធ្វើការរាប់អានឲ្យបានទូលំទូលាយពិតមែន តែមនុស្សទាំងអស់ មិនមែនជាមិត្តជិតស្និទ្ធរបស់យើងទេ ប៉ុន្តែក្នុងការនិយាយ ត្រូវមានក្នុងក្រៅ ។

www.elibraryofcambodia.org

● បើគ្មានសេចក្ដីស្នេហាបរិសុទ្ធ មិនចេះបញ្ជាសេចក្ដីស្នេហា ជីវិតរបស់យើងនឹងជួបប្រទះនូវបរាជ័យស្ទើរគ្រប់អន្លើគួរឲ្យស្ដាយ ។

● ទោះបីជួបឧបសគ្គធ្ងន់ធ្ងរយ៉ាងណា យើងគប្បីក្លាហានពុះពារ ចេះចាត់ចែងឲ្យហ្មត់ចត់ ដើម្បីប្រតិបត្តិឆ្លងកាត់ឧបសគ្គនោះទៅ ។

● ខាងក្នុងត្រូវឲ្យរឹង ប៉ុន្តែខាងក្រៅត្រូវទន់ភ្លន់ បង្ហាញនូវសភាពថ្លៃថ្នូរនឹងរួសរាយចំពោះមនុស្សម្នាក់ៗ ។

● មនោគតិរបស់មនុស្ស វាហក់លោតដូចជាសេះដាច់បង្ហៀរ ប៉ុន្តែយើងត្រូវយកសុភនិច្ឆ័យនិងគតិបណ្ឌិត នឹងសភាពនឹងនមកគ្របដណ្ដប់វា ដើម្បីឲ្យមានថាមពលល្អ ។

● យើងចង់មានមិត្តភក្ដិល្អ មានសហការីល្អ មិត្តត្រូវមានសេចក្ដីទៀងត្រង់និងចិត្តអនុគ្រោះឲ្យទូលំទូលាយ ។

● មធ្យោបាយធ្វើសត្រូវឲ្យទៅជាមិត្ត គឺមិនត្រូវប្រើវិសមានចិត្តប្រឆាំងនិងវិសមានចិត្តទេ ត្រូវស្ងាត់ស្ងៀម, អនុគ្រោះ, ទន់ភ្លន់, សណ្ដោសប្រណីក្នុងករណីអចេតនា ។

www.elibraryofcambodia.org

● ក្នុងការនិយាយជាមួយនឹងមនុស្សម្នាក់ ទោះការធម្មតាឬសំខាន់ក៏ដោយ មិត្តត្រូវនិយាយឲ្យច្បាស់លាស់ និយាយត្រឹមត្រូវចេះការពារសំដី ហើយត្រូវរួសរាយ ។

● ជ័យជំនះនៅក្នុងជីវិតមនុស្ស មិនមែនកើតឡើងតែពីជំនះវិជ្ជា ការរៀនសូត្រច្រើននោះទេ វាត្រូវមានចរិយាល្អ បុគ្គលិកលក្ខណៈល្អ និងការរាក់ទាក់រួសរាយប៉ិនប្រសប់ ។

● មនុស្សយើងធម្មតាមិនស្រឡាញ់គ្នា តែចូលចិត្តបានបេះដូងគ្នា ។

● ស្រឡាញ់មែនទែនគឺគ្មានខ្វាចចិត្ត នឹងគ្មានស្តាយអ្វីទាំងអស់ចំពោះមនុស្សដែលខ្លួនស្រឡាញ់ ។

● សត្វឆ្កែដែលបានមនុស្សចូលចិត្ត មកអំពីវាស្ម័ស្មាប់នឹងមនុស្ស , ដើរទៅរកមនុស្ស, រួសរាយ, ចេះដោរ . . . ផ្ទះ, មនុស្សបើចង់ឲ្យគេស្រឡាញ់ខ្លួន គេជួយកិច្ចការខ្លួន ត្រូវចេះស្ម័ស្មាប់នឹងគេ, ទៅរកគេ, យល់ថាគេសំខាន់, រាប់អានរាក់ទាក់នឹងគេ យកចិត្តគេ ។

● នៅក្នុងជីវិត មិនត្រូវរក្សាគំនិតបោកប្រាស់គេទេ ប៉ុន្តែ

www.elibraryofcambodia.org

មានករណីខ្លះគេគេចមិនរួច ។

● កិច្ចការអ្វីទាំងអស់មិនត្រូវទះដៃផយោ ឬខិះខៀនរិះគន់ដោយចិត្តស្រឡាញ់ឬស្អប់នោះទេ គេត្រូវពិចារណាឲ្យល្អិតល្អន់មុននឹងធ្វើ ។

● គ្មានមធ្យោបាយណាទិញទឹកចិត្តមនុស្សឲ្យបានទៀងទាត់បោយយួរអង្វេងស្មេនឹងសេចក្តីសោះត្រង់ក្នុងរឿងស្នេហាទេ

● កុំឲ្យស្មានថា ៖ មនុស្សកើតសម្លាប់គ្នាហើយរាប់អានគ្នាវិញមិនកើតឲ្យសោះ ពីព្រោះមនុស្សត្រូវគ្នានាំផលប្រយោជន៍។

● មិនត្រូវនិយាយអំពីសាសនា, ជនៀនិងនយោបាយទេក្នុងករណីដែលជួបរាប់អានគ្នាជាលើកដំបូង ។

● មនុស្សយើងអាចអន់ចិត្តនឹងគ្នា ហើយបែកបាក់គ្នាយ៉ាងងាយ ពីព្រោះតែរឿងកំប៉ិកកំប៉ុកយកទៅធ្វើជារឿងធំដុំ ។

● រស់នៅឬរាប់អានជាមួយនឹងមនុស្សថោកទាប ទោះបីយ៉ាងណាអ្នកដែលខ្ពង់ខ្ពស់ក៏ត្រូវខូចខាតដែរ ។

● មិនអាចយល់គ្នាបានអស់រវាងមនុស្សស្រីនឹងមនុស្សប្រុស ទោះប្តីប្រពន្ធក៏ដោយ បើកាលណាហើយយើងមិនចេះពិនិត្យ ។

www.elibraryofcambodia.org

បើចេះអត់ទោស គឺរិតតែចេះស្រលាញ់ច្រើនថែមទៅទៀត ។

## បទវិចារណ៍

● យុវជនតែងប្រាថ្នា ៖ ស្នេហា ប្រាក់កាស និងសុខភាព តែដល់ថ្ងៃណាមួយនោះ គេត្រឡប់ជាថា ៖ សុខភាព ប្រាក់កាស នឹងស្នេហានៅក្រោយទៅវិញ ។

PAUL G

● ការឃើញជាលើកតម្កើងហើយចាប់ចិត្តស្រលាញ់ភ្លាម គឺជាទីបញ្ចប់នៃការចេះដឹង ។

ANTOINE BRET

● អ្នកណាដែលមិនស្រលាញ់ស្រី មិនស្រលាញ់ចំរៀង និងមិនចេះសុរា ។ អ្នកនោះជាមនុស្សឆ្កួតម្នាក់ក្នុងជីវិតរបស់គាត់ ។

## ២ បទវិចារណ៍

● អ្នកដែលស្រលាញ់សេចក្តីសប្បាយច្រើន តែងតែក្រ ។

ENGLISH BROVERB

www.elibraryofcambodia.org

● អ្នកណាដែលមិនព្រមទទួលផ្កាកុលាប អ្នកនោះមុខជាទទួលបន្លាវិញជាមិនខាន ។

DANISH PROVERB

● មិនមានភ្លើងឯណាដូចភ្លើងតណ្ហាឡើយ ។

GAUTAMA

● កូនទាំងអស់គ្នាមានអានឬទេថា : មុនដំបូងព្រះម្ចាស់សួគ៌បានបង្កើតប្រុសម្នាក់ ស្រីម្នាក់ ហើយលោកបានបង្គាប់ថា : មកអំពីហេតុនោះហើយបានជាប្រុស ចោលម្ដាយឪពុកទៅតាមប្រពន្ធខ្លួន ហើយអ្នកទាំងពីរនោះទៅជាសាច់តែមួយ ។

JESUS CHRIST

● បេះដូងត្រូវដើរមុនស្មារតី ហើយចិត្តសប្បុរសត្រូវដើរមុនធម៌សច្ចៈ ។

JOUBERT

● កុសលវាមានចំពោះតែសំឡាញ់ពីរនាក់ ដែលស្រឡាញ់គ្នាយ៉ាងខ្លាំង ហើយស្លាប់រស់ដើរជាមួយគ្នា ។

CH. PEGUY

www.elibraryofcambodia.org

● បើអ្នករស់នៅម្នាក់ឯងហើយរក្សាមិនបាន ឬទ្រាំមិនរួចនូវសេចក្ដីស្មោះត្រង់ចំពោះតណ្ហា ល្អជាងយើងត្រូវមានគ្រួសារ មានគ្រួសារល្អជាងទុកឲ្យភ្លើងតណ្ហាក្រាសទាញប្រចណ្ឌប្រចាំង ។

I COR — VII, 9

● ក្នុងពេលមានវិបត្តិខាងខួរក្បាល (ឧត្តមគតិ) គេត្រូវការមនុស្សឲ្យបានញាប់ឬឃោចល់ ជាជាងមិត្តជួយរយផ្ទាំ (ប្រពន្ធ) ។

BENJAMIN

● នៅក្មេងមិនមែនបានន័យថា យើងទើបតែមានអាយុមួយឆ្នាំនោះទេ ការពិតគឺជាអត្យាស្រ័យនៃបេះដូងទេតើ ! ។

SERTILLANGES

● សត្វមានញីឈ្មោល មនុស្សមានស្រីប្រុស ។

បទវិចារណ៍

● ទឹកក្រខ្វក់មួយស្វាបព្រា អាចធ្វើឲ្យក្រខ្វក់ទឹកស្អាតមួយពាង ។

PROVERBE MALGACHE

www.elibraryofcambodia.org

● គេមិនអាចធ្វើមាន ដោយប្រការដែលប្រវញ្ចគេទ គឺដោយប្រការដែលគេឲ្យ ។

J. FLORY

● អនុស្សាវរីយ៍ណាដែលជាអនុស្សាវរីយ៍ត្រជាក់ត្រជុំជាងគេបំផុត? គឺព្រោកដជាការសប្បាយរីករាយ ដែលគេឲ្យយើង ។

Mme DIANE

● បេះដូងអត្តទត្ថភាព មិនអាចគេចផុតពីការផ្ដល់ទោសនៃសេចក្ដីទុក្ខព្រួយទេ ។

GOETHE

● នៅកន្លែងណាមានការមិនស្មោះត្រង់ នៅកន្លែងនោះមានផុកនៅក្នុងផ្ទះខ្មោច ។

LA CORDAIRE

● មានតែចិត្តថ្លើមទូលំទូលាយនោះទេ ដែលអាចយល់បានថា: « ចិត្តល្អ » គឺជាកិត្តិយស ។

FENELON

● មនុស្សមានគុណលើយើង ៗ គួរខ្លាចជាងសត្រូវទៅ

www.elibraryofcambodia.org

ទៀត៖ ខ្វាចពេលណាដែលយើងគ្មានពេលទៅសងគុណនោះ ។

J.J. ROUSSEAU

● សុភមង្គលនៅក្នុងមនោគតិ. គឺជាសុភមង្គលពិតប្រាកដ។

FONTANES

● ការឈឺចាប់នាំឲ្យស្មារតីយើងមានការធូរស្រាល ហើយខ្ពង់ខ្ពស់ ។

LAMARTINE

● បើមេត្តាច្រើន គឺស្រឡាញ់ខ្លាំង ។

Mme DE STAËL

● ការរស់នៅដែលទទួលសេចក្តីសុខមួយមុខប៉ុណ្ណោះ គឺជាការរស់ទទួលបរាជ័យពិតប្រាកដ ។

J. CHARDONNES

● បើយើងពិនិត្យតែលទ្ធផលខាងក្រៅហើយ យើងធ្វើការរិះទៀនចំពោះសេចក្តីស្នេហា យើងនឹងឃើញថា៖ វាហាក់ដូចជាសត្រូវផ្គួនគ្នាជាជាងការស្រឡាញ់ ។

LA ROCHE FOUCAULD

www.elibraryofcambodia.org

● ការស្រឡាញ់ខ្លួន ( Amour propre) វានាំឲ្យអន្តរាយដល់ស្រីមួយភាគធំ ជាជាងសេចក្តីស្នេហា ។

LA ROCHE FOUCAULD

● អ្នកណាលើកជើងបញ្ជោរយើង អ្នកនោះឯងជាសត្រូវនឹងយើង ។

GARDAN

● ការចូលចិត្តលើកជើងបញ្ជោរ ភាគច្រើននាំឲ្យអន្តរាយស្ត្រីភេទជាជាងសេចក្តីស្នេហា ។

LAVIS

● ខ្ញុំចូលចិត្តការយល់សប្តិ បើវាអាចឲ្យសុភមង្គលដល់ខ្ញុំជាជាងការពិតដែលនាំឲ្យខ្ញុំឈឺចាប់ ។

LA ROCHE FOUCAULD

● សភាវៈគតិមានភ្នែករាប់រយពាន់ ហើយបេះដូងមានមួយដែរ ទីបំផុតនៃជីវិតទាំងមូលរលត់បាត់នៅពេលដែលស្នេហាឈានជើងចូលមក ។

F.W. BOURDILLON

www.elibraryofcambodia.org

● ពេលចុងក្រោយនៃជីវិតលើវជាអនុស្សាវរីយ៍ មិនអាចបំភ្លេចបានរបស់ស្រីខ្វះ ដែលបានស្គាល់នូវជីវិតដ៏ប្រសើរ ។

ANONYME

● តែតណ្ហាមកគ្រប់គ្រងចិត្តហើយតែងច្បាំងដណ្តើមយកឈ្នះវិចារណញ្ញាណជានិច្ច ។

PAPE

● ម្នាក់ៗ តែងនិយាយថាសុភមង្គល។ ប៉ុន្តែច្រើនគ្នាណាស់ឥតយល់នឹងស្គាល់នូវជំរៅសុភមង្គលទេ ។

Mme JANNE P

● តើសុភមង្គលនៅត្រង់ណា ? បើគេទិញដោយការឈឺចាប់គិតច្បច្រើន ។

PUNNI

● ខ្ញុំរៀនរកសុភមង្គលរបស់ខ្ញុំ ដោយដាក់ព្រំដែនដល់តណ្ហារបស់ខ្ញុំ ជាជាងឲ្យការសាកល្បងចំពេញបំណងនៃតណ្ហា ។

JOHN STUART MILL

www.elibraryofcambodia.org

● ប្រុងប្រយ័ត្នមិនមានធន្ទះ គឺការចែចង់ ។

MAX O'RELL

● សូមនិយាយជាភាសាបុជាវិញ ។

## ពាក្យស្លោករបស់អ្នកលក់ផ្កា

● តើអ្វីហ្នឹងធ្វើឲ្យឯងខ្លាចញញើត , កូន! គ្រូម្នាក់សួរទៅសិស្សខ្លួន ហ៊ឺ / លោកគ្រូ, ចុប្បាប់ព្រៃទាំងនេះ! សិស្សឆ្លើយដោយស្ញៀមស្ងាត់ ។

PETER. NEWELL

● លាគ្នាថ្មបែកគ្នាហាក់ដូចស្លាប់ពាក់កណ្ដាល ។

SHAKESPEARE (ROMEO-JULIET)

● បើគេស្រម័យអំពីការចែចង់ គឺនៅតាមដងទន្លេ«សែន» នាក្រុងប៉ារីស ។

ANONYME

● សូមអញ្ជើញមកនៅក្នុងបេះដូងខ្ញុំមក! ហើយខ្ញុំមិនបាច់គិតដល់ថ្លៃឈ្នួល ។

SAMUEL LOVER

www.elibraryofcambodia.org

● ដាក់ទោសដោយសេចក្ដីក្ដៅក្រហាយ មិនមែនជាការដាក់ទណ្ឌកម្មទេ គឺជាការសងសឹកទេតើ ។

LAROUSSE ROCPEFORT

● រូបល្អនាំឲ្យសប្បាយភ្នែក ស្មារតីនាំឲ្យសប្បាយរីករាយ , ការរំភើបចិត្តនាំឲ្យស្រើប , មានតែចិត្តសប្បាយប៉ុណ្ណោះទេដែលនាំឲ្យអាឡោះអាល័យ ។

PETRARQUE

● មនុស្សកំណាញ់ មិនព្រមដាក់ទានអ្វីដល់អ្នកណាមួយសោះ អ្នកនោះគឺជាសត្រូវទី ១ របស់ខ្លួនឯង ។

LA BRUYERE

● និយាយអំពីសេចក្ដីវេទនារបស់ខ្លួនចេញ គឺបានន័យថា: លួងលោមខ្លួនរួចហើយ ។

ALEXANDRE DUMASPERE

● ពាក្យសំដីមនុស្សយើងវាធាប់ត្រូវគ្នាណាស់ ប៉ុន្តែអំពើធ្វើទើបត្រូវគ្នា ។

MOLIERE

www.elibraryofcambodia.org

● បើយើងឈឺចុកចាប់ខ្លាំងខ្លួនមាននរណា យើងត្រូវគិតថា ៖ មានគេ

វេទនាជាងយើងច្រើនទៅទៀត ។

Mme DE MAINTENON

www.elibraryofcambodia.org

## អនាមិក ANONYME

● ស្រឡាញ់បរិសុទ្ធគេគ្មានទើសទាល់ ឬស្តាយវត្ថុអ្វីទេចំពោះមនុស្សដែលគេស្រឡាញ់ ។

● កុំសរសើរ ឬបង្អាប់មនុស្សណាដោយចិត្តយើងស្រឡាញ់ ឬស្អប់ ឬដោយសារពាក្យចចាមអារាម ។ ត្រូវចេះពិចារណាឲ្យជ្រាលជ្រៅ យ៉ាងហ្មត់ចត់ច្បាស់លាស់ ។

● គ្មានវិធីទិញទឹកចិត្តមនុស្សឯណា ឲ្យមានប្រសិទ្ធិភាពស្មើនឹងសេចក្តីស្នេហា ឬការស្រឡាញ់រាប់អានស្មោះត្រង់ឡើយ ។

● វិធានលេខមួយយ៉ាងប្រសិទ្ធិ ក្នុងការកសាងកិត្តិយសនឹងការកសាងបុគ្គលិកចរិយាឲ្យគេគោរព គឺការប្រយ័ត្នពាក្យសំដី។

● មនុស្សយើង ជួនកាលមានការអាក់អន់ចិត្តនឹងគ្នា បែកបាក់គ្នា ពីព្រោះតែចិត្តប្រកាន់ច្រើនពេក ពីព្រោះតែរបស់កំប៉េកកំប៉ុក ។

www.elibraryofcambodia.org

● រស់នៅជាមួយ ឬទាក់ទងសេពគប់ជាមួយនិងមនុស្សអនខ្សោយ ទោះបីយ៉ាងណាមនុស្សថ្លៃថ្នូរ ក៏ត្រូវខាតប្រយោជន៍ដែរ ។

● មិនចាំបាច់ឲ្យគេរហ័សស្គាល់យើងពេកទេ ក៏មិនចាំបាច់ឲ្យគេគោរពយើង ក្នុងពេលដែលយើងនៅខ្ចីនៅឡើយដែរ ។ យើងគិតតែពីរៀបចំចរិយាសម្បត្តិ នឹងវិជ្ជាសម្បត្តិឲ្យស្រួលបួលទៅ គេនឹងគោរពហើយទទួលស្គាល់យើងជាមិនខាន ។

● មនុស្សណាចេះ « ឲ្យ » មួយ អាចទទួលមកវិញបានយ៉ាងច្រើនរាប់ពាន់ ។

● ដើម្បីជ័យជំនះ មិនមែនគេត្រូវការតែនិយាយឬត្រូវការតែឲ្យឈ្នះអ្នកដទៃនោះទេ ! ក្នុងករណីខ្លះគេត្រូវនៅស្ងៀម គេត្រូវចុះចាញ់ដែរ ដើម្បីទីបំផុតបានជ័យជំនះយ៉ាងប្រសើរ ។ បានសេចក្តីថា : យើងត្រូវចេះចាញ់តូចដើម្បីផ្តើមយកឈ្នះធំ ។ ជួនកាល យើងនៅស្ងៀមខំអត់តែប្រាំនាទី ស្មើនឹងយើងប្រឹងនិយាយសម្រុះសម្រួលដល់ទៅ ៥ ថ្ងៃ ។ សុខចិត្តខាតតិចតួចតែបានប្រយោជន៍ច្រើនទៅអនាគត ។

www.elibraryofcambodia.org

● ត្រូវប្រយ័ត្ន មនុស្សដែលយករឿងអាក្រក់ពីគេមកប្រាប់យើង ថ្ងៃណាមួយរឿងអាក្រក់របស់យើងក៏នឹងត្រូវគេនាំយកទៅនិយាយប្រាប់គេអីចឹងដែរ ។

● បើមិត្តជាមនុស្សក្លាហានធ្លាប់ទាក់ទង ឡើងចុះជាមួយមនុស្សធំ,មនុស្សច្រើន មានពាក្យសំដីវោហារច្រើន ប៉ុន្តែមិត្តនោះគេបាត់សភាពធម្មតាចំពោះមុខស្ត្រីរូបល្អ ខ្ញុំមិនអាចហៅមិត្តថាជាៈវីរបុរសបានឡើយ ។

● ស្នេហាមិនមែននៅលើប្រាក់កាស ប៉ុន្តែគេក៏មិនអាចស្នេហា ហើយទៅផឹកទឹកទន្លេបានដែរ ។

● ដល់ទីបំផុត ទឹកទន្លេគេមិនអាចក្លាឲ្យទៅជាបាយម៉ានបានទេ ។

● គ្មានអ្វីឈឺចាប់ឲ្យស្មើនឹងស្នេហា ដែលត្រូវគេបោះបង់ចោល, ស្នេហាត្រូវគេក្បត់ ត្រូវគេរមិលគុណយើងទេ ។

● គេមិនអាចស្រឡាញ់ស្រីពីរនាក់ ហើយឆ្លើយអួតថា : ខ្លួនស្មោះត្រង់នោះទេ ។

● ចង់ឲ្យគេស្រឡាញ់យើង ស្តាប់បង្គាប់យើងប្រការ

www.elibraryofcambodia.org

ពិសេសត្រូវប្រយ័ត្នពាក្យសំដី ត្រូវមានធម៌មេត្តានឹងត្រូវរាងរៃ ។

● មានមនុស្សភាគខ្លះ ត្រូវគេនិយាយសំអុយមួលបង្កាច់ក៏ច្រឡោតតោគក្នុងប្រកែកប្រណាំងរកឬសរកគល់ខុសត្រូវ .. ធ្វើរបៀបនេះនាំឲ្យបាក់កិត្តិយស ។ យើងត្រូវឲ្យនឹងធឹងឬនៅស្ងៀមក៏បានដែរ ទីបំផុតជ័យជំនះបានមកយើង ។

● មនុស្សធ្វើម្ចាស់ខ្លួនយើងបាន ចេះបញ្ជាខ្លួនយើងបាន ទោះបីរស់នៅកន្លែងណា ក្នុងពេលណាក៏ដោយ ក៏គេសប្បាយរករាយចិត្តដែរ ។

● ធ្វើបួកបែបឆ្លាត គឺជាមនុស្សមហាល្ងង់ ចេះធ្វើល្ងង់គឺជាមនុស្សមហាឆ្លាត ។

● មិនចេះអត់អោនការតូចតាច ជ័យជំនះធំនឹងត្រូវអន្តរាយ ។

● ស្នេហ៍ស្និទ្ធ បរិសុទ្ធ, ពលិកម្ម សហប្រតិបត្តិការអស់ទាំងនេះហើយដែលជាលក្ខណៈនាំឲ្យមានមិត្តឧត្តមគតិ នាំឲ្យជ័យជំនះក្នុងដំណើរជីវិត ។

● កុំភ័យនឹងពាក្យគេថា ,, យើងមិនចេះ, យើងក្រ, យើងអាក្រក់ ,, ។ ខ្វាចតែយើងមិនចេះមែន, យើងក្រមែន, យើងអាក្រក់

www.elibraryofcambodia.org

មែននោះទេ ! ។

● គេមិនត្រូវ : «គ្មានអ្វីមិនដឹងមិននិយាយ គ្មានអ្វីមិននិយាយ មិននិយាយឲ្យអស់ » ។

● មានតម្រេះតែមិនចេះប្រើ នាំឲ្យអន្តរាយដល់ខ្លួនយើង ។

● បើយើងធ្វើម្ចាស់អណ្ដាតយើងបាន បានសេចក្ដីថាយើងធ្វើម្ចាស់ខ្លួនយើងបានពាក់កណ្ដាលហើយ ។

● កុំខឹងផ្ដេសផ្ដាស ទោះបីនៅក្នុងករណីគួរខឹងក៏ដោយត្រូវប្រើសំដីឲ្យបានធម្មតា នោះមិត្តមុខតែអួសទាញបេះដូងគេបាន ។

● មនុស្សគមិនចេះនិយាយ ប៉ុន្តែមនុស្សចេះនិយាយជួនកាលគេធ្វើត ។

● ចេះកំប្លែងជាការល្អប្រសើរ ប៉ុន្តែកំប្លែងខុសវេលាវារមែងជាមនុស្សមានចរិយាអន់ កិត្តិយសត្រូវអន្តរាយ ។

● យើងចេះទ្រាំទ្រនឹងការយល់ច្រឡំរបស់មនុស្ស គឺជាការល្អមួយហើយ ប៉ុន្តែយើងត្រូវចៀសវាងនូវអំពើណាដែលនាំឲ្យគេយល់ច្រឡំនោះ វាកាន់តែល្អថែមទៅទៀត ។

● ប្រព្រឹត្តល្អដាក់គ្នាជាការធម្មតា ប៉ុន្តែមិត្តមានធ្លាប់ឬទេ

www.elibraryofcambodia.org

ហេតុអ្វីក៏មនុស្សនោះធ្វើល្អដាក់យើងខ្លាំងម៉េះ ? ការធ្វើល្អដាក់យើង ជួនកាលគេចង់បានប្រយោជន៍ពីយើង ឬគេបំផ្លាញយើង ។

● យើងមិនត្រូវទុកឲ្យប្រាក់កាស ការស៊ីផឹក, ការក្តៅក្រហាយ មកបំផ្លាញមិត្តភាពរបស់យើងឲ្យសោះ ព្រោះវានាំឲ្យយើងថោក គេមើលងាយ ។

● កុំស្តាយពេលវេលាបន្តិចបន្តួច ឬប្រាក់កាសបន្តិចបន្តួចនោះ ពីព្រោះការខាតបន្តិចបន្តួចនេះហើយដែលនាំឲ្យបានជ័យជំនះធំ ។

● នៅក្នុងលោក គ្មានមនុស្សណាមួយមានអំណាចមកបង្ខិតបង្ខំឲ្យយើងសន្យាប្រការណាមួយឡើយ ។ ប៉ុន្តែស្ម័គ្រចិត្តសន្យានឹងគេហើយ ត្រូវខំប្រឹងរក្សាឲ្យទៀងទាត់ ការសន្យាមិនទៀងទាត់វានាំឲ្យថោកទាប ។

● ការចូលចិត្តពីរយ៉ាងដ៏គ្រោះថ្នាក់គឺ : ចូលចិត្តនិយាយច្រើន នឹងចូលចិត្តប្រព្រឹត្តកាមច្រើន បើយើងធ្វើម្ចាស់វាបាន យើងមុខតែនឹងបានជ័យជំនះធំ ។

● ប្រការអ្វីដែលយើងមិនស្គាល់ យើងកុំអាលថាជាប្រការ

www.elibraryofcambodia.org

អាក្រក់ យើងត្រូវពិនិត្យវាសិនទើបយើងដឹងបានច្បាស់ ។

● ប្រាក់ជាម្ចាស់អាក្រក់ ប៉ុន្តែជាអ្នកបំរើល្អ ។

● មិនត្រូវខំប្រឹងចៀសវាងតែអំពើអាក្រក់ណា ដែលសង្គមមនុស្សគេដឹងនោះទេ សូម្បីតែអំពើអាក្រក់ដែលមានតែយើងម្នាក់ដឹង ក៏ត្រូវតែខំចៀសអីចឹងដែរ ។

● ធ្វើការអ្វីៗត្រូវប្រយ័ត្ន ប៉ុន្តែ ប្រយ័ត្នមិនបានសេចក្តីថា : មិនធ្វើនោះទេ ។

● និយាយឲ្យតិច ធ្វើឲ្យច្រើន មិត្តនឹងបានគេស្រលាញ់ច្រើនគ្នា ហើយគ្មានអ្នកណាម្នាក់ ដែលគេយកមកប្រៀបនឹងមិត្តឡើយ ។

● ក្នុងការនិយាយជាមួយនឹងសត្រូវ ឬនិយាយផ្ទាញ់ផ្ទាលដោយប្រការអ្វីមួយ គេថ្លឹងសំដីដូចគ្នាថ្លឹងមាស ។

● យើងមិនត្រូវភ្ញាក់ផ្អើល នឹងពាក្យចចាមអារាមនៃមហាជនពេកទេ ពិសេសពាក្យចចាមអារាមរបស់សត្រូវ ឬមនុស្សដែលស្អប់យើង ។

● ស្នេហាគឺជាម្ចាស់អាក្រក់ តែវាជាខ្ញុំបំរើល្អ ។

www.elibraryofcambodia.org

● បង្កើតការសាមគ្គី វាងាយជាងរក្សាការសាមគ្គីឲ្យបានស្ថាពរ ។

● មនុស្សដឹងគុណយើង ជួនកាលជាមនុស្សគោរពយើង ប៉ុន្តែគេជាមនុស្សចេះគោរព ។

● បទភ្លេងទាំងអស់សុទ្ធតែពីរោះ ពីព្រោះវាមិនមែនពីរោះតែជាមួយនឹងយើងនោះទេ ។

● ទ្រាំ . . . ទ្រាំ . . . ស៊ូទ្រាំ បានចំជាមនុស្សក្លាហាន មនុស្សធម្មតាមិនចេះស៊ូទ្រាំទេ មានតែអ្នកចេះដឹងប៉ុណ្ណោះ ។

● ជានិច្ចជាកាល ត្រូវយកចិត្តទុកដាក់ក្នុងការគោរពខ្លួនយើង ។ បើយើងមិនគោរពខ្លួនយើងទេ អ្នកក្រៅក៏គ្មានអ្នកណាគោរពយើងដែរ ត្រូវប្រុងប្រយ័ត្នជាពិសេសចំពោះពាក្យសំដីនឹងអាកប្បកិរិយា ដែលនាំឲ្យបុគ្គលិកលក្ខណៈរបស់យើងត្រូវចុះតម្លៃបំផុតនៅក្នុងករណីណាដែលតណ្ហាវាភ្ញាក់ផ្អើល ឬផលប្រយោជន៍វាយកជិះជាន់ ។

● នៅក្នុងជីវិតមនុស្សគ្មានអ្វីជាសុក្រិត ( Parfait ) ទេ ហេតុនេះ នៅក្នុងគំនិតរបស់យើងក៏មិនត្រូវមានការស្មានជាសុក្រិត

www.elibraryofcambodia.org

អីចឹងដែរ ។ មនុស្សណាយល់ថាៈ នៅក្នុងជីវិតមនុស្សមានសុក្រឹតភាព . . . អ្នកនោះឯងជាមនុស្សនៅឆោត ឬមនុស្សដែលមានការសិក្សានៅខ្ចី ។

● អ្វីដែលយើងមិនចេះ បើយើងសួរគេ យើងត្រូវស៊ូទ្រាំនៅស្ងៀមស្ដាប់គេពន្យល់ កុំជជែកឬប្រកែកថាមិនបានការ ។

● មហាក្សាហានគឺហ៊ានទទួលខុសត្រូវ ចំពោះកំហុសរបស់ខ្លួន រាល់ថ្ងៃយើងត្រូវខំហាត់ធ្វើយ៉ាងណាកុំឲ្យមានគំនិតលាក់ពុតឬលាក់កំហុសរបស់ខ្លួន ឬទម្លាក់កំហុសរបស់ខ្លួនយើងទៅឲ្យមនុស្សផ្សេង ។

● មហាក្សាហានគឺជាអាកប្បកិរិយាឧមុតាចំពោះបរាជ័យ ឬជ័យជំនះ ។

● កិច្ចការរបស់គេ ក្នុងពេលដែលគេមិនត្រូវការដល់យើង យើងមិនត្រូវលូកដៃចូលទេ ត្រូវមានគំនិត ស្រេចតែគេឬនុកឲ្យគេធ្វើទៅ បើមិនដូច្នោះទេ ការចេះដឹងរបស់យើងនឹងទៅជាថោកទាប ។

● ត្រូវចេះញញឹមជានិច្ច ត្រូវមានទឹកមុខស្រស់សំរឺស្រាយ

www.elibraryofcambodia.org

ជាធម្មតា ដើម្បីឲ្យអ្នកក្រៅគេយល់ថា យើងជាមនុស្សត្រឹមត្រូវ ។

● ស៊ីផ្លែឈើត្រូវគិតទៅដល់អ្នកដាំវាផង ។

● ចំពោះបរាជ័យគ្រោះថ្នាក់គឺការធុញទ្រាន់ . . . យើងពិចារណាមើល បើឃើញថាគ្មានផ្លូវចៀសវាងរួចទេ យើងត្រូវក្លាហាន ហើយពុះពារដើរឆ្លងកាត់ដោយរីករាយ កុំគប្បីថ្ងូរថ្ងូរក្តៅក្រហាយឬសោកស្តាយឡើយ ពីព្រោះបរាជ័យក៏ជាមេរៀនយើងដែរ ។

● ត្រូវហាត់ឲ្យចិត្តយើងទូលាយ អ្វីៗដែលល្អិតល្មោចតូចតាចឬស្មុគស្មាញបន្តិចបន្តួច មិនសំខាន់ដល់ឧត្តមគតិនៃការរស់នៅ យើងត្រូវចំបាត់វាចោលទៅ ឬកុំយកចិត្តទុកដាក់នឹងវា ទើបយើងអាចធ្វើការធំដុំបាន ។

● កុំបណ្តោយខ្លួនឲ្យការសោកស្តាយ ឬសេចក្តីសង្ស័យវាមកអូសទាញបេះដូងយើងខ្លាំងពេក ។ ការតាំងចិត្តជាធម្មតា វាអាចនាំឲ្យយើងភ្លីស្មាង មិនតក់ស្លុត មិនខ្វល់ខ្វាយ . . . កិច្ចការបានសម្រេច ។

● គេត្រូវចៀសវាង « គ្មានអ្វីមិនដឹងមិននិយាយ គ្មានអ្វីមិន

www.elibraryofcambodia.org

និយាយ មិននិយាយឲ្យអស់» ។

● គេមិនអាចក្រវទឹកទន្លេឲ្យទៅជាបាយម៉ានបានទេ ដីវាប ណាគ្មានផាតិម្សៅ ។

● ត្រូវចាក់សោទ្វារមនោសញ្ចេតនាយើងឲ្យជាប់ ។ ការ រស់នៅរបស់យើងរាល់ថ្ងៃត្រូវឲ្យធម្មតា កុំឲ្យអ្នកក្រៅគេយល់បាន នូវការផ្លាស់ប្ដូរខាងផ្លូវចិត្តរបស់យើង ដោយអាកប្បកិរិយា ។

● បើយើងធ្វើម្ចាស់អណ្ដាតយើងបាន បានន័យថាយើង ធ្វើម្ចាស់ខ្លួនយើងបានពាក់កណ្ដាលហើយ ។

● មិត្តខំប្រឹងកុំខឹងផ្ដេសផ្ដាស ទោះបីក្នុងពេលដែលត្រូវខឹង ក៏ដោយ ខំប្រឹងនិយាយស្ដីឲ្យធម្មតា គឺជាព្រះអរហន្ត, មនុស្ស គេចពីស្រឡាញ់យើងមិនរួចទេ ។

● គេមិនអាចស្រឡាញ់មនុស្សពីរនាក់ឲ្យស្មើគ្នាបានទេ ។

● មនុស្សនៅស្ងៀម ដោយមិនចេះធ្វើម្ចាស់ខ្លួនឲ្យបានដល់ កាលណានិយាយច្រើនតែនិយាយខុសផ្ដេសផ្ដាស ។

● មនុស្សណានៅស្ងៀមពីព្រោះគេយល់ គេធ្វើម្ចាស់ខ្លួន គេបាន ដល់ពេលគេនិយាយ គេនិយាយសុទ្ធតែត្រូវ ។

www.elibraryofcambodia.org

រស់នៅក្នុងសង្គមមនុស្ស មានពេលខ្លះយើងខឹងនឹងមនុស្សនៅជុំវិញយើងដោយគ្មាគ្មានកំហុសសោះ ពីព្រោះតែយើងស្រឡាញ់ខ្លួនយើងពេក, ប្រកាន់ផ្ដេសផ្ដាសច្រើនពេក ហើសយល់ខុសខ្លាំងពេក ។

● ក្នុងករណីដែលយើងត្រូវគេយល់ច្រឡំ គេថ្កោលទោស, ប្លុលពុក, គេកំហុសយើង គេមួលបង្កាច់យើងគេសំឡុតយើង ។ យើងមិនត្រូវមានគំនិតតបទៅវិញ ដោយកម្លាំងអាវុធឡើយ ក៏ដូចជាសំដីជេរបញ្ចោរបញ្ចិតបញ្ចៀង, យើងត្រូវឲ្យធម្មតា ពិចារណាឲ្យវែងឆ្ងាយ អាកប្បកិរិយាធម្មតានេះហើយដែលនាំឲ្យបានជ័យជំនះជាទីអវសាន ។

● ស្អប់ក៏ទុក្ខ ស្រឡាញ់ក៏ទុក្ខ ពីព្រោះស្អប់និងស្រឡាញ់គឺតែមួយ ។

● នៅក្នុងជីវិតមនុស្សរាល់ថ្ងៃ មានពេលខ្លះដោយសារតែតណ្ហាឬផលប្រយោជន៍បន្តិចបន្តួច អាចនាំឲ្យយើងបាត់ផលប្រយោជន៍ធំដុំយ៉ាងសំខាន់ ។ គ្រាន់តែខំពិចារណាបន្តិចប៉ុណ្ណោះ យើងអាចយល់បាននូវផលប្រយោជន៍ធំដុំក្លាយ ។

www.elibraryofcambodia.org

● បន្ទាប់ពីការជួយឧបត្ថម្ភមនុស្សម្នាក់ហើយ ត្រូវគេសងមកវិញ ដោយអាកប្បកិរិយាអកត្តញ្ញូមករកមិត្តវិញ អាកប្បកិរិយារបស់មិត្តពេលនេះត្រូវឲ្យធម្មតា ការពារគ្រោះថ្នាក់ នៅស្ងៀមមិនព្រមនិយាយអាក្រក់តបទៅវិញ ចាំពិចារណាមើល ។

● ឧសរកមួយឆ្នាំ ផុតតែមួយថ្ងៃ ។ កិត្តិយសរបស់មនុស្សក៏ដូច្នោះដែរ យើងខំកសាងតាំងពីតូចមក អស់ពេលយ៉ាងវែងដល់ចាស់ទុំទៅ ធ្វើអំពើអ្វីផ្ដេសផ្ដាសតូចមួយ អាចនាំឲ្យកិត្តិយសរលាយទៅជាផ្សែងអស់មួយភ្លែត ។

● ទេវតាគឺជាសការៈ ដែលច្រើនតែត្រូវមនុស្សគេមើលងាយ គេមិនរាប់អានដល់ គេមិនយកចិត្តទុកដាក់ក្នុងពេលដែលគេបានសុខ បានសុភមង្គល . . . ។ ផ្ទុយទៅវិញ ទេវតាក៏ជាកំពង់ផែជួយសង្គ្រោះមនុស្សជាទីបំផុត ក្នុងពេលដែលមនុស្សត្រូវឈឺចាប់ ។

www.elibraryofcambodia.org

# បុរសស្ត្រីប្តីប្រពន្ធ

● ហេតុដែលគូស្នេហា មិនចេះនឿយណាយក្នុងការជួបគ្នាពីព្រោះគេនិយាយតែអំពីរឿងរបស់គេទាំងពីរនាក់ ហើយគេចេះភាសាពិសេសរបស់គេតែគេពីរនាក់ដែរ ។

LAROCHE FOUCAULD

● ជាការប្រសើរណាស់ ដល់ស្ត្រីណាដែលរៀបការជាមួយនឹងបុរសម្នាក់ដែលគេស្រឡាញ់រូបនាង ជាជាងនាងរៀបការជាមួយនឹងបុរសម្នាក់ ដែលនាងស្រឡាញ់គេ ។

ARAB PROVERB

● ទីណាក៏ដោយឲ្យតែបងទៅ ប្អូនក៏ទៅតាមបងជានិច្ច ។ ទីណាក៏ដោយឲ្យតែបងនៅ ប្អូនក៏រស់នៅក្បែរបងជានិច្ច ។ គ្រួសារបងគឺជាគ្រួសារប្អូន អ្វី ៗ ដែលបងស្រឡាញ់ ប្អូនក៏ស្រឡាញ់ដែរ ហើយធ្វើតាមបងទាំងអស់ ។ ចំណែកឯរូបប្អូនវិញ សុំតែសេចក្តីមេត្តានឹងស្មោះត្រង់ពីបងប៉ុណ្ណោះ ។

LETTRE DE MISS S.

www.elibraryofcambodia.org

● ជីពចររបស់ស្ត្រីដែលខ្ញុំស្រឡាញ់ វារត់ស្មើនឹងចិត្តនឹងនួនដ៏ខ្ជាប់ខ្ជួនបំផុតរបស់ស្ត្រីដែលស្រឡាញ់ខ្ញុំ ។

GEORGE BERNARD SHAW

● នារីក្មេកខៀវថា ស្រឡាញ់ខ្ញុំ ឬខ្ញុំស្លាប់ . . . ។ នារីក្មេកខ្មៅថា ស្រឡាញ់ខ្ញុំឬ ខ្ញុំសម្លាប់អ្នក ។

SPANISH PROVERB

● ស្ត្រីខ្លះរៀនខ្មាស ក្នុងពេលដែលឃើញគូស្នេហារបស់គេមកដល់ ។

● ខ្លះរត់ប្រេបល់ទៅប្តឹងភ្នាក់ងារ ប៉ូលិស

● ខ្លះចិត្តរឹងរ៉ិះរេទំស្ងៀចស្ងៀរ

● ខ្លះគ្មាន់ខ្ញាញ់ខាំកគេរ ប៉ុន្តែត្រូវប្រយ័ត្ននារីណាដែលសើចច្រើនមិនចេះឈប់ ។

បទរិចារណ៍

● ប្តីប្រពន្ធគឺជាមិត្ត ១០០ ឆ្នាំ បើមានការខុសឆ្គងតិចតួចគួរបានវែងឆ្ងាយពិចារណាហើយកុំប្រកាន់ ។

បទរិចារណ៍

www.elibraryofcambodia.org

● មនុស្សស្រី ធម្មជាតិបង្កើតឡើងមុនដំបូងបង្អស់ គឺដើម្បីការស្រឡាញ់ ដើម្បីធ្វើប្រពន្ធ និងដើម្បីធ្វើម្ដាយ ។

P. GILLET

● មានស្ត្រីខ្លះ មិនព្រមលែងប្ដីពេញច្បាប់របស់ខ្លួនទេ ប៉ុន្តែចូលចិត្តមានប្រុសមិនព្រមឈប់ដែរ ។

PAUL TRACTIF

● នៅក្នុងជីវិតប្ដីប្រពន្ធ បើយើងពិចារណាអំពីសីលធម៌វិញ យើងឃើញឥតគុណនានូវការបោកបញ្ឆោតភូតភរ ឆ្លៀតយកប្រយោជន៍ពីគ្នា . . . បំផុតគឺនៅក្នុងពេលដែលអ្នកទាំងសងខាងនៅក្មេងនៅឡើយ ច្រើនធ្វើជាខ្ញុំបំរើនៃសេចក្ដីស្នេហាទៅវិញ ។

H. BENEDICTIN

● កាលនៅពីក្មេង ស្ត្រីនិងប្រុសមើលសេចក្ដីស្នេហាឃើញជាល្បែងកំសាន្ត ។ ប៉ុន្តែ បើខ្វះការពិចារណាឲ្យត្រឹមត្រូវគេមុខតែនឹងត្រូវល្បែងកំសាន្តនេះសងគុណយ៉ាងជូរចត់វិញមិនខាន ។

R. CASIMIR

www.elibraryofcambodia.org

● មានស្ត្រីប្រពន្ធគេខ្លះ ក្នុងពេលមកនៅផ្ទះខាងប្ដីគិតតែបំរើរៀងគណ្ហា : តុបតែងកាយ ស៊ីផឹកខ្ជះខ្ជាយរ៉េតន់នេះនោះ នាំឲ្យប្ដីបាត់ស្មារតី . . . គេគ្មានជួយប្ដីក្នុងកិច្ចការឲ្យបានចំរើនទាល់តែសោះ ។

MENTHERFES

● ខ្ញុំនឹងដូរមុខរបរឬកាយចរិយារបស់ខ្ញុំ ដើម្បីឲ្យបានសុខស្រួលក្នុងពេលដែលខ្ញុំបានដឹងថា : នៅកន្លែងមួយនោះ មានស្ត្រីម្នាក់ព្រួយចិត្តកើតទុក្ខ ពីព្រោះតែខ្ញុំមកផ្ទះយ៉តយូរខុសពេល ។

TOUR GUENIEF

● យុវជនម្នាក់ខំថែរក្សាសេចក្ដីបរិសុទ្ធរបស់ខ្លួន ឲ្យបានដល់ខ្លួនមានអាយុ : ២០ ឆ្នាំ ។ យុវជននេះជាមនុស្សល្អបរិសុទ្ធជាទីគួរឲ្យចូលចិត្តនៃមនុស្សដែលនៅជុំវិញ ។

J.J ROUSSEAU.

● ប្រាកដជាមកអំពីមនុស្សស្រីនេះហើយ ដែលនាំឲ្យទៅជាមានទុក្ខទោស ។ ហើយក៏ពីព្រោះតែមនុស្សស្រីនេះដែរ ដែលនាំឲ្យប្រុសៗ ត្រូវស្លាប់ ។

ECCL. XXV 33

www.elibraryofcambodia.org

● គ្មានកូនជញ្ជីងឯណាថ្លឹងបាននូវតម្លៃ នៃព្រលឹងដ៏បរិសុទ្ធរបស់មនុស្សបានទេ ។

ECCL.XXVI - 20

● រូបសម្រស់ដ៏ឆើតឆាយ នៃស្ត្រីដែលមានចរិយាល្អម្នាក់ គឺជាព្រះច័ន្ទដែលបញ្ចាំងរស្មីទៅឲ្យគ្រួសារយ៉ាងថ្លៃថ្នូររបស់ខ្លួន ។

ECCL. XXVI – 21

● ដើម្បីចៀសវាងជម្ងឺកាមគុណ មនុស្សប្រុសត្រូវមានប្រពន្ធតែមួយ មនុស្សស្រីត្រូវមានប្ដីតែមួយ ។

ST. PAUL

● ប្ដីឧត្តមគតិ ( ប្ដីជាទីគាប់ចិត្ត ) គឺជាមនុស្សដែលមានសហប្រតិបត្តិការជាមួយនិងប្រពន្ធ ក្នុងវត្ថុបំណងពង្រីកសមត្ថភាពរបស់ខ្លួន , កសាងសុភមង្គលឲ្យខ្លួន , គ្រួសារខ្លួននឹងសង្គមមនុស្ស ។

CAJOLIN

● យុវជនដែលទើបតែនឹងគ្រប់អាយុពេញការ មានវត្ថុបំណងពីរគឺ : រកទទួលទានចិញ្ចឹមជីវិតនឹងបំរើតណ្ហា បើគេ

www.elibraryofcambodia.org

អាចផ្ទៀតរកបានមុនពេលរៀបអាពាហ៍ពិពាហ៍ ។

JACQUES LECLERCQ

● បើចង់ការប្រពន្ធគួរជ្រើសលក្ខណៈ ស្ដីដូចតទៅនេះៈ ឧស្សាហ៍ ព្យាយាម ស្មោះត្រង់ ចិត្តមួយថ្លើមមួយ ចេះគិតវែងឆ្ងាយដោយល្អិតល្អន់ សុភនិច្ច័យ ។

NARARDIN

● គេដួលភ្លឹងចុះចាញ់ចំពោះមុខមនុស្ស ដែលពូកែ ប៉ុន្តែគេលត់ជង្គង់សំពះចំពោះចិត្តមេត្តា ។

GOUNOD

● មិត្តកុំមើលងាយស្ត្រីម្នាក់ ដែលមានចិត្តស្រាលប្រយ័ត្នធ្លាក់ជាប់សំណាញ់ស្រីនោះ ។

ECCL. IX — 5

● មិត្តកុំមើលងាយស្ត្រីម្នាក់ ហើយកុំស្មានថារូបសម្រស់របស់ស្ត្រីនោះ មិនអាចអូសទាញខ្លួនយើងបានឡើយ ។

ECCL. IX-5

● កុំសំលៀងការបិតបង្ខាត់ប្រពន្ធ កុំសម្លាប់ផ្លែនាស់គៀនប្ដី។

បទវិចារណ៍

www.elibraryofcambodia.org

● ប្រពន្ធស្លូតនាំឲ្យប្ដីចេះ ប្រពន្ធកាចនាំឲ្យប្ដីខូច ។

THAI CONG

● ស្រួលរស់នៅជាមួយនឹងខ្លាជាមួយនឹងក្រពើ ល្អជាងរស់នៅជាមួយនឹងមនុស្សស្រីកាច ។

ECCL. XXV – 23

● ស្ត្រីគឺជាអ្វី ? គឺជាកូនក្មេង គេនាំឲ្យវាសប្បាយដោយល្បែងលេង គេបំពេរវាដោយពាក្យសំដីសន្យាពីរោះ ។ វាយំដោយសារតែរឿងកំប៉េកកំប៉ុក វាខឹងដោយសារតែមានរឿងប្រឆាំង ហើយវាសងសឹកដោយសារតែមានការមិនចុះសម្រុង មិនព្រមស្ដាប់តាមសំដីវា ។ នេះជានិច្ចជាកូនក្មេងមែន ប៉ុន្តែគឺជាគុនកូនក្មេងដែលមានឥទ្ធិពលធំបំផុតលើមនុស្សលោក ។

GRIMOD DE LA REYNIERE

● មូលហេតុនៃស្នាដៃធំ ៗ ទាំងអស្សារ្យណានៅក្នុងលោកយើងនេះ សុទ្ធតែមានទាក់ទងដល់រឿងស្រីទាំងអស់ ។

LAMARTINE

www.elibraryofcambodia.org

● ឆាប់ស្រឡាញ់គ្នាពេក ហើយមិនរៀបការភ្លាមទុកឲ្យនៅចាំយូរពេក មិនខុសណានឹងឡានតាក់ស៊ីបរនៅពេលខ្យល់ព្យុះ ហើយមានភ្លៀងធំនោះទេ ។

VANPAUL RICHTER

● គេស្រឡាញ់តែម្តងទេ ស្នេហាបន្ទាប់ ៗ មកទៀតគឺជាសេចក្តីស្នេហា ដោយបង្ខំទាំងអស់ ។

LABRUYERE

● កាមតណ្ហាមិនខុសណានឹងកម្លាំងទឹក : តែយើងសង្កត់វាខ្លាំងកាលណា វាមានកម្លាំងកាន់តែខ្លាំងកាលនោះ ។

QUINAULT

● ស្ត្រីមិនត្រូវទទួលអំណោយអ្វីមួយ ពីមនុស្សណាទេពីព្រោះបេះដូងវានឹងរីកធំក្នុងពេលដែលល្វកនៃទទួលយក ហើយបេះដូងនោះទៀត មុខជាត្រូវកម្លាំងមនុស្សប្រុសនោះអូសទាញជាមិនខាន ។

LAFONTAINE

● កូនសោបើកទ្វារទូដែក ក៏ជាសោបើកចិត្តមនុស្ស

www.elibraryofcambodia.org

បានដែរ ។

LAFONTAINE

• ស្ត្រីណាហ៊ានយកអំណោយរបស់មនុស្សប្រុសណាមួយ គឺស្ត្រីនោះហ៊ានជំពាក់បំណុលមនុស្សប្រុសនោះ ដែលមានពេលខ្លះហ៊ានរហូតដល់ទៅយកខ្លួន ទៅសងមនុស្សប្រុសនោះទៀតផង ។

Mme DE GIRARDIN

• ស្ត្រីណាហ៊ានទទួលប្រាក់កាសពីមនុស្សប្រុស ស្រីនោះហ៊ានប្រគល់អាយុជីវិតរបស់ខ្លួន ឲ្យទៅមនុស្សប្រុសនោះហើយ ។

Mlle DE LESPICASSE

• ស្ត្រី ៗ ប្រុងប្រៀបខ្លួនជាស្រេច នឹងសរសេរមនុស្សប្រុសណាដែលសរសេរគេ ។

J J ROUSSEAU

• ស្ត្រី ៗ មិនខុសណានឹងលោកវរជនធំទេ គេខំលើកដើងស្ត្រី ៗ ពីព្រោះគេចង់បានចំណេញ ។

ROCHE BRUNE

www.elibraryofcambodia.org

● មនុស្សប្រុសសាញប្រដាញច្រើនពេក គំនិតល្អិតល្អន់ហើយ កំបើកកំប៉ុកចំពោះគ្រួសារច្រើនពេក ប្រុសនោះគឺជាមនុស្សធុនអន់ ។ ផ្ទុយទៅវិញ បើមនុស្សស្រីសាញប្រដាញច្រើនគឺជាមនុស្សល្អ ។

LATENA

● មនុស្សស្រី តែកាលណារមិលគុណចំពោះអ្នកមានគុណ គឺមិនមែនស្រីទេ ។

FONTANES

● សុភមង្គលរបស់មនុស្សស្រី គឺភាគច្រើននៅត្រង់ចំនួនមនុស្សដែលលើកជើងបបោសអង្អែលគេ ។

ROCHE BRUNE

● គេអាចអត់ទោសបានទាំងអស់ ចំពោះមនុស្សស្រីដែលគេស្រឡាញ់ពិត ។ ហើយក៏ពីព្រោះតែរឿងនេះដែរ ដែលស្នេហាបែរទៅជាតឹងទ្រូងដកដង្ហើមមិនចង់ចេញ ។

J. CHARDONNES

● រស់នៅឯកោម្នាក់ឯងមិនសូវគួរឲ្យខ្លាច ដល់មនុស្សដែល

www.elibraryofcambodia.org

ទទួលការអកុសលពីគ្រួសារខ្លួននោះទេ ។

DANIELGRAY

● មនុស្សប្រុសត្រឹមត្រូវ អាចមានស្នេហាដូចមនុស្សឆ្កួត ប៉ុន្តែមិនអាចមានស្នេហាដូចជាមនុស្សល្ងង់ឡើយ ។

LAROCHE FOUCAULD

● រូបសម្រស់របស់នារី មិនខុសណានឹងក្លិនក្រអូបរបស់ផ្កាទេ វាបក់មកម្តង ៗ រួចវារសាយបាត់ទៅនៅក្នុងខ្យល់ បើកាលណាយើងធ្លាប់ហិតខ្លិនវាហើយ យើងមិនរវល់គេទោទៀតទេ។

Mme DE LAMBERT

● ចិត្តរបស់ស្ត្រីដូចគ្នានឹងមហាសមុទ្រសែនជ្រៅ បាតសមុទ្ររាក់ផងម៉េចក៏មនុស្ស មិនអាចដឹងអស់បាន ។

RICCOBION

● គ្មានអ្វីគ្រោះថ្នាក់ឲ្យស្មើនឹងឃើញមនុស្សស្រីម្នាក់ មានរូបល្អហើយឈឺចាប់ ។ ការអាណិតអាសូរ អាចក្លាយទៅជាស្នេហាយ៉ាងងាយណាស់ ។

Mme DE SARTORY

www.elibraryofcambodia.org

● ស្រី ៗ ដែលពាក់មាសពេជ្រច្រើនពេក គេពិបាកនឹងយល់ថា : តើគេស្រឡាញ់ខ្លួនដោយសារអ្វី ?

Mme DE RIEUX

● មនុស្សស្រី ហេតុអ្វីក៏យកចិត្តទុកដាក់តែអំពីរូបល្អរបស់ខ្លួននោះម៉្លេះ ? ។ ពីព្រោះមនុស្សប្រុសស្រឡាញ់គេ ក៏តែពីរឿងនោះដែរ ។

Mme DE LAMBERT

● នារីល្អគឺជាស្ថានសួគ៌នៃចក្ខុ តែវាក៏ជានរកនៃចិត្តរបស់មនុស្សដែរ ។

POPE

● នារីដែលមានរូបល្អពេក ពិបាកនឹងរស់នៅឲ្យបានសុខស្រួលណាស់ , មាសពេជ្រក៏ជាចំណីអាហារនៃពួកចោរខ្លាំងដែរ។

J-J ROUSSEAU

● មនុស្សស្រីមានស្មារតីអត្តទត្ថភាព គឺជាសត្វចង្រៃមួយ, ពីព្រោះអាទិទេពបានបង្កើតមនុស្សស្រីមក មិនមែនសម្រាប់ខ្លួនគេទេ គឺសម្រាប់សុភមង្គលអ្នកដទៃ ។

M lle DE LESPINASSE

www.elibraryofcambodia.org

● គេនិយាយល្បួងលួងលោមមនុស្សស្រី ដោយការបោកបញ្ឆោត ប៉ុន្តែគេផ្អាញ់ផ្អាលមនុស្សស្រីដោយការស្មោះត្រង់ ។

NERAL

● ជ្រើសរើសបានប្ដីម្នាក់ល្អជាការលំបាក ប៉ុន្តែរក្សាប្ដីនោះឲ្យនៅជានិច្ចជាមួយនឹងយើងវាកាន់តែលំបាកខ្លាំងទៅទៀត ។

J.CHARDONNES

● សេចក្ដីរាប់អានមិត្តភាពរវាងស្ត្រីម្នាក់ នឹងប្រុសម្នាក់ភាគច្រើនវាគ្រាន់តែជានាមសម្រាប់និយាយភូតកុហកទេ ការពិតគឺគេបិទបាំងនូវសេចក្ដីស្នេហាមួយ ដែលគេមិនទាន់ហ៊ាននិយាយចេញនៅឡើយ ។

MARCEL PROUST

● មនុស្សប្រុសដែលត្រូវស្នេហាវាជិះជាន់ហើយ មិនខុសណានឹងចង្កៀងឡានដែលភ្លឺតែម្ខាង ។

LOUIS DE ROBERT

● ល្អគឺជាអ្វី ? ចំពោះមនុស្សស្រីមួយភាគធំ ល្អគឺជាអ្វីដែលមនុស្សនៅជុំវិញគេយល់ថាល្អ ។

LOUIS DE ROBERT

www.elibraryofcambodia.org

● កុំយកប្ដីដែលមានតម្រេះវិជ្ជា នឹងចរិយាខ្សោយជាងខ្លួនយើងឲ្យសោះ ហើយក៏កុំយកប្រពន្ធដែលមានតម្រេះនិងចរិយាបញ្ញាវាងវៃជាងយើងឲ្យសោះដែរ ។

LATENA

● បានមនុស្សប្រុសថ្នាក់ថ្នមយកចិត្តទុកដាក់ មិនមែនជាការអន់ខ្សោយថ្មបោកទាំងទេ ការការពារថ្នាក់ថ្នម វាជានិមិត្តរូបមួយនៃការមានតម្លៃ ដែលមនុស្សត្រូវការថែរក្សាកុំឲ្យបាត់ ។ ស្ដេចជាម្ចាស់ផែនដី មេទ័ព នាយទាហាន . . . ចង់បានគេថ្នាក់ថ្នមការពារជាងរាស្ត្រសាមញ្ញមែនឬទេ ? ផ្កាដែលគេដាក់ក្នុងផ្ទះ ក្នុងកញ្ចក់ តើចង់បានការថ្នាក់ថ្នមបបោសអង្អែលជាង ផ្កានៅក្នុងព្រៃមែនឬទេ ? ។ តើមាសប្រាក់ដែលយើងចង់បាននោះ មកអំពីវាត្រូវគេថែរក្សាថ្នាក់ថ្នមជាងវត្ថុផ្សេងៗទៀតមែនឬទេ ? ។

GINA LOMBROSO

● ស្ត្រីនឹងបុរសមិនអាចយល់គ្នាបានអស់ទេ ពីព្រោះអ្នកទាំងពីររស់នៅក្នុងសាកលលោកពីរផ្សេងពីគ្នា ។

GINA LOMBROSO

www.elibraryofcambodia.org

● ស្រីដែលប្រកាន់ច្រើនហើយចិត្តស្រាល ជានន័យថា កាយកប់នូវសុភមង្គលរបស់គ្រួសារខ្លួនដោយចង្អមនិងកញ្ចក ។

បទវិចារណ៍

● ទីណាមានស្រី ទីនោះមានស្នេហា ។ ហើយទីណាមានស្នេហា ទីនោះក៏មានទុក្ខផែរ ។

បទវិចារណ៍

● បើចង់បានសុភមង្គលនៅក្នុងគ្រួសារ បើចង់បានប្ដីប្រពន្ធល្អមានឧត្តមគតិ ប្រការពិសេសគឺយើងត្រូវតែងខ្លួនយើងឲ្យទៅជាប្រពន្ធ ឬជាប្ដីមានឧត្តគតិល្អជាមុនសិន ។

LELEND FOSTER WOOD

● មនុស្សស្រីដែលងាយបំផុត គឺជាមនុស្សស្រីដែលពិបាកបំផុត ។ មនុស្សដែលមិនកាច់រៀង គឺជាមនុស្សដែលចេះកាច់រៀងជាងគេទាំងអស់ ។ មនុស្សដែលមិនសូវតែងខ្លួន គឺជាមនុស្សដែលចេះតែងខ្លួនជាងគេទាំងអស់ ។

A. MAUROIS

● តាមការពិត ការលួចស្រឡាញ់គេ វាក៏មានការឈឺ

www.elibraryofcambodia.org

ចាប់ផ្ដើមចត់ដែរ ប៉ុន្តែវាក៏ជាការសប្បាយមានសុភមង្គលដោយស្ងាត់ស្ងៀមអីចឹងដែរ ។

## បទវិចារណ៍

• កាលវ័យនៅក្មេង យើងពិបាកនឹងយល់បាននូវជម្រៅនៃសេចក្ដីស្នេហាណាស់ ចំពោះមនុស្សក្មេងសេចក្ដីស្នេហាគឺជាភ្លើងចម្បើង វានេះឡើងរួចវារលត់ទៅវិញភ្លាម ។

STENDHAL

• ស្ត្រីរង់ចាំប្រុស ប៉ុន្តែរង់ចាំដូចគ្នានឹងពីងពាងពាក់មង ។

BERNARD SHAW

• បើមនុស្សប្រុសចេះស្រឡាញ់ចរិយា ឲ្យដូចជាគេស្រឡាញ់ស្រីរូបស្អាត មនុស្សប្រុសនោះសមនឹងក្លាយទៅជាទេវតាហើយ ។

ROCHESTER

• ការឈឺចាប់របស់ស្ត្រីរូបល្អ គ្មានការណាឈឺចាប់ឲ្យជាងឃើញរូបស្ត្រីម្នាក់ទៀត ដែលមានរូបល្អជាងខ្លួននោះទេ ។

PH. DE VARENEN

www.elibraryofcambodia.org

● ចំពោះមនុស្សស្រីដែលគេបានស្រឡាញ់ហើយ គ្មានស្ត្រីណាមានរូបអាក្រក់ទេ ។

RONSARD

● តែស្រឡាញ់ហើយគឺល្អទាំងអស់ ។

បទវិចារណ៍

● ទឹកភ្នែកគឺជាអាវុធយ៉ាងមុតបំផុតរបស់ស្ត្រីភេទ ។

SAINT EVREMOND

● ប្រុស ៗ ដែលស្ងៀកពាក់កាច់រៀង ឆើតឆាយខ្លាំងពេក គំនិតរបស់គេច្រើនមានការបោកប្រាសនៅពេលខ្លះ ។

Mme DE SALM

● ការធ្វើឲ្យស្រី ៗ បានល្អជានិច្ច គឺការណាដែលធ្វើឲ្យប្រុស ៗ ស្មោះត្រង់ជានិច្ច ។

SCRIBE

កុំទៅស្បថថា យើងស្រឡាញ់គេជាស្ថា ពរនោះគ្មានអ្នកណាហ៊ាននិយាយថា : ស្នេហាវាមិនចេះប្រែប្រួលនោះទេ ។

SENAN COURT

www.elibraryofcambodia.org

ស្ត្រីគឺជាស្ពកបាយដែលមនុស្សមើលឃើញខុសគ្នា គេស្រេកឃ្លានមុនពេលបរិភោគ គេខ្ពើមល្អើមកាលណាគេបរិភោគរួចហើយ ។

HELVELTIUS

ស្ត្រីគឺជាវត្ថុមួយដែលគេពិបាកឲ្យន័យណាស់

Mme DE LAMBERT

អ្នកណាដែលស្អប់មនុស្សស្រីច្រើនជាងគេ គឺអ្នកនោះឯងហើយដែលស្រឡាញ់ស្រីច្រើនជាងគេ ។

EMILE DESCHANEL

គេនិយាយអាក្រក់ពីស្រីគ្មានអ្វីដាក់អស់ទេ ប៉ុន្តែក៏គ្មានមនុស្សណាមួយដែលរស់នៅហើយខ្វះមនុស្សអាក្រក់នោះដែរ ។

ADOPHE RICARD

ចំពោះស្ត្រីគេទ បើមិនបានគេស្រឡាញ់ខ្លួនទេ នោះក៏ជាគ្រោះថ្នាក់មួយហើយ ។ ប៉ុន្តែបើសិនណាជាត្រូវគេស្អប់វិញ នោះបានចំជាមានគ្រោះថ្នាក់មែន ។

MONTESQUIEU

www.elibraryofcambodia.org

សរសើរស្ត្រីណាមួយផ្សេង ចំពោះមុខស្ត្រីដែលគេស្រឡាញ់យើង គឺជាទោសកំហុសមួយធំណាស់ដែលមិនអាចអត្យាស្រ័យបានឡើយ ។

Mme DE STAEL

មានរបៀបសរសើរស្ត្រីមួយយ៉ាង ដែលគេចូលចិត្តបំផុត គឺ : និយាយអាក្រក់ពីស្រីណា ដែលគេស្អប់ថាសត្រូវរបស់គេ ។ កំពុងតែនិយាយសរសើរស្រីម្នាក់ចំពោះមុខ ហើយត្រឡប់ទៅជានិយាយសរសើរស្រីម្នាក់ទៀត ការនិយាយសរសើររបស់យើងនោះគ្មានផលល្អ គ្មានបានប្រយោជន៍អ្វីទាំងអស់ ។

Mme DE GIRARDIN

មនុស្សស្រីដូចគ្នានឹងផ្កា បានតែជះក្លិនក្រអូបនៅវេលាយប់ប៉ុណ្ណោះទេ ។

LA MENNAIS

ព្រះអាទិទេពលោកបង្កើតមនុស្សស្រីមក បែបដូចជាសម្រាប់គេស្រឡាញ់ផងផាងខ្លួនស្រឡាញ់គេ ។ ដូចគ្នានឹងផ្កា សម្រាប់

www.elibraryofcambodia.org

គេក្រអឺបជាជាងក្រអឺបខ្លួនឯង ។

ALPHONSE ESQUIROSE

ស្ត្រីភេទមិនខុសណា នឹងស្រមោលរបស់យើងទេ បើយើងរត់តាមវា វាចោលយើងឲ្យនៅក្រោយខ្នង បើយើងរត់ហួននឹងវា វាត្រឡប់ជារត់តាមពីក្រោយខ្នងយើងវិញ ។

D'ARLIN COURT

មនុស្សប្រុសណាដែលលើកជើងបញ្ជោរស្រី ។ ច្រើនជាងគេ គឺមនុស្សប្រុសនោះហើយ ដែលមានចិត្តមើលងាយមនុស្សស្រីច្រើនជាងគេ ។

MEIL HAN.

● ប្ដីប្រពន្ធស្រុះសចិត្តគំនិតគ្នា ទោះចឹសមុទ្រក៏បាចរីងដែរ ។

## បទវិចារណ៍

១ មនុស្សស្រីដែលព្រះអាទិទេពបង្កើតមក មុនដំបូងបង្អស់គឺដើម្បីបានកេស្រឡាញ់ បន្ទាប់មកគឺដើម្បីធ្វើជាប្រពន្ធនឹងធ្វើជាម្ដាយ ។

P. GILLET

www.elibraryofcambodia.org

● មនុស្សប្រុសដែលព្រះអាទិទេពបង្កើតមក មុនដំបូងបង្អស់គឺដើម្បីស្រឡាញ់គេ បន្ទាប់មកដើម្បីតស៊ូក្នុងមុខការដើម្បីធ្វើប្តី នឹងដើម្បីធ្វើឪពុក ។

WATERSTONE

● ឲ្យមក ប្រគល់បុរសនោះមកឲ្យខ្ញុំ ពីព្រោះគាត់មិនមែនជាទាសៈនៃតណ្ហាទេ ។

SHAKES PEARE (HAMLET)

● ឱ អូនភ្លេចហើយឬយ៉ាងណា ? ការដែលប្អូនកាចតឹងរឹងដាក់បង ។ ឱ ! អូនដឹងឬទេ ! ថ្ងៃនេះហើយដែលយើងត្រូវបែកគ្នា ប្រហែលជាច្រើនឆ្នាំ ឬក៏រហូតមួយជីវិតក៏មិនដឹង ។ ឱ ! យ៉ាងហ្នឹងហើយនៅតែប្អូនឈរស្ងៀមទៀត : សំដីអូនសំឡេងអូនជាបេះដូងរបស់បង និយាយប្រាប់បងមកព្រលឹង ។

JULIA CRAWFORD

● រាត្រីសួស្តីអូន រាត្រីសួស្តីបង រាត្រីសួស្តីលាគ្នាតែពិរោះហួសនិស្ស័យ បែកគ្នាដូចស្លាប់ពាក់កណ្តាលខ្លួន បងលាបណ្តោះអាសន្ន ទំរាំថ្ងៃស្អែកជួបគ្នា ។

SHAKES PEARE (Ranes Juliet)

www.elibraryofcambodia.org

● ប្រពន្ធ - ភាគខ្លះគឺជាសាហាយស្មន់របស់យុវជនភាគខ្លះគឺជាមិត្តសម្រាប់ជីវិតរបស់បុរសក្នុងមជ្ឈិមវ័យ ខ្លះទៀតជាគ្រូពេទ្យសម្រាប់ផ្គត់ផ្គង់របស់មនុស្សចាស់ ។

BACON

● កូនស្រីដែលមិនចេះធ្វើការអ្វី ៗ ក្នុងផ្ទះ នឹងទៅជាស្ត្រីមេផ្ទះ មិនចេះវិជ្ជាមេផ្ទះ ។

FRANKLIN

● បុរសដែលដឹងកិច្ចការតិចតួច អ្នកនោះនឹងរាយរ៉ាប់ប្រាប់ភរិយាគេឲ្យច្រើន លើសពីការដែលគេដឹងទៅទៀត ។

THOMAS FALLER

● ស្វាមីល្អត្រូវចេះធ្វើថ្លង់ ភរិយាល្អត្រូវចេះធ្វើខ្វាក់នោះសុភមង្គលនឹងមានមួយជីវិត ។

FRENCH. PROVERB

● ស្វាមីល្អ មិនមែនជាអ្នកចូលនិទ្រាមុនភរិយាក្នុងពេលរាត្រី ហើយមិនមែនជាអ្នកភ្ញាក់ក្រោយគេនៅពេលព្រឹកនោះទេ ។

BALZAC

www.elibraryofcambodia.org

● បុរសជាស្វាមីត្រូវតែខ្ពស់, ចាស់ ធូន់ ហើយអាក្រក់ជាងភរិយាខ្លួន ។

E.W. HOWE

● តែស្វាមីយ៉ាងណា ភរិយាក៏យ៉ាងនោះដែរ ។

TENNYSON

● នៅទីណាដែលអស់ផ្កាហើយ បុរសមិនអាចរស់នៅបានទេ ។

NAPOLEON

● ស្រីទាំងឡាយ ត្រូវតែចេះប្រសប់ក្នុងការរៀបចំប្តីឲ្យបានល្អ នឹងឲ្យគេតែតែស្រឡាញ់ខ្លួន ។

BALZAC

● ស្ត្រីច្រើនតែយំសោកនៅពេលមុនរៀបការ ចំណែកឯបុរសវិញច្រើនតែយំសោកបន្ទាប់ពីថ្ងៃរៀបការមក ។

POLISH PROVERB

● តណ្ហាទី ១ របស់ស្ត្រីគឺ ស្រឡាញ់គូស្នេហារបស់គេ បន្ទាប់មកស្ត្រីស្រឡាញ់សេចក្តីស្នេហា ។

BYRON

www.elibraryofcambodia.org

● ស្រីគឺជាស្រមោលរបស់យើង បើយើងតាមវា ៗ គេចរត់ចេញ បើយើងគេចពីវា ៗ រត់រកយើង ។

CHAMFORT

● បុរសតែងនិយាយអំពីអ្វីដែលស្រីចូលចិត្ត ចំណែកស្ត្រីវិញ ក៏ច្រើនតែធ្វើអ្វីដែលប្រុសចូលចិត្តដែរ ។

DESUPUR

● ស្ថានសួគ៌គ្មានការច្រឡោតខឹងដូចស្ត្រី ៗ ខឹងនោះទេ ស្ថាននរកក៏គ្មានការខឹងក្រេវក្រោធដូចស្ត្រី ៗ ស្រែកជេរដែរ ។

CONGREVE

● វណ្ណៈស្រីជាន់ខ្ពស់ គឺគេសំដៅទៅលើឫកពារ ។

GOETHE

បុរសណាដែលបញ្ជើតបញ្ជើរស្រីណាមួយ បុរសនោះមិនស្គាល់ស្រីនោះទេ ។

Mme DE SALUR

● ជាការងាយណាស់ ស្ត្រីអាចការពារគុណធម៌និងព្រហ្មចារីយ៍របស់ខ្លួនបានចំពោះមនុស្សប្រុស ប៉ុន្តែស្រីមិនងាយ

www.elibraryofcambodia.org

នឹងរក្សាកិត្តិនាមរបស់ខ្លួនបាន ចំពោះស្រីដូចគ្នានោះទេ ។

ROCHE BRÜNE

● ប្រមាថមើលងាយស្រី ស្រីមិនចេះអត់ទោសឲ្យទេ, បង្ខំស្រី ស្រីស្អប់យើងអស់មួយជីវិត ។

PAPE

● ភាពស្រួយហើយងាយប្រែប្រួលគឺឈ្មោះ « ស្រី » ។

SHAKES PEARE (CLEOPATRA)

● ឈើច្រាប់បំផុតស្រីដែលមកដល់ក្លាម ហើយវាយឬក ធ្វើឲ្យស្មើនឹងយើង រួចធ្វើចៅហ្វាយយើង ។

CATO THENSOR

● បុរសមានធន្ទះ ស្រីមានរបៀប ជាវត្ថុពិបាករកបាន ។

HOLMES

● កំហុសធំរបស់ស្ត្រី គឺចង់ធ្វើឲ្យដូចបុរស ។

DEMAISTRE

● ស្រីអាចអត់ទោសការផេរប្រទេចបាន ប៉ុន្តែគេមិនអាច

www.elibraryofcambodia.org

អត់ទោសដល់ការពាយងាយរបស់បុរសទេ ។

HALIBURTOW

● បុរសតែងចង់នៅផ្លូវក្តៅ ប៉ុន្តែគេរៀបការនៅផ្លូវត្រជាក់វិញ ។

SHAKES PEARE (Asyoulikei)

● កំហុសមុនដំបូងរបស់ប្តីប្រពន្ធ គឺការខ្វះការិះនិងការដែលយើងជួយគ្នាដោយសោះកក្រោះពេក មុនពេលដែលយើងបានស្និទ្ធស្នាលនឹងគ្នា ។

## បទវិចារណ៍

● មនុស្សដែលខុសពួកនឹងយើង មានសម្បុណ៌ដូចស្រមោច ប៉ុន្តែមនុស្សជាមិត្ត ១០០ ឆ្នាំ នឹងយើងពិបាករកដូចគ្នានឹងរកពេជ្រ ។

WATERSTONE

● គេតែងស្រឡាញ់អ្នកណា ដែលកោតសរសើរគេប៉ុន្តែគេមិនសូវស្រឡាញ់អ្នកណាដែលគេបង្ខំចិត្ត ត្រូវតែនិយាយសរសើរ

www.elibraryofcambodia.org

នោះទេ ។

LA ROCHE FOUCAULD

● ស្រឡាញ់អាត្មាឯង នឹងស្រឡាញ់ពិភពលោកទាំងមូល ឬក៏បង្កើតស្ថាននរកមួយទៀត ។

SWEDENBERG

● ចំពោះការស្រឡាញ់ឬការស្អប់ ស្ត្រីភេទគ្មានមជ្ឈគតិទេ។

SYRUS

● បើចង់ដឹងថាយើងស្រឡាញ់គ្នាមែនឬទេ យើងសាកល្បងឃ្លាតគ្នាមួយគ្រាមើល បើចិត្តសង្វេគក្រហល់ក្រហាយច្រាសច្រាលនៅមិនស្ងៀម នោះស្នេហាវាបានឈានជើងចូលមកហើយ ។

## បទវិចារណ៍

ស្នេហាគឺជាសត្វមួយយ៉ាងចម្លែក បើគេទុកឲ្យវាស្រេកឃ្លាន វាមានជីវិតរស់នៅបានយូរ បើគេឲ្យវាឆ្អែតឆ្អន់ វាស្លាប់បាត់ភ្លាម ។

A. DE MUSSET

www.elibraryofcambodia.org

• ស្នេហាគឺជាធុងប្រេងសាំង យើងកុំគប្បីយកឈើគូស ទៅគូសលេងជិតឲ្យសោះ ។

បទវិចារណ៍

## ស្នេហា

• ស្នេហាគឺជាកូនទេវតាក្រ ប៉ុន្តែវាក៏ជាកូនទេវតាមាន ដែរ ។ កូនទេវតាក្រ : បានជាវារហេមរហាមវាទាមទារ, វាសុំរំលែក ។ កូនទេវតាមាន : បានជាវាទូលាយដៃទូលាយ ជើងខាងប្រាក់កាស់ ចំពោះមនុស្សដែលខ្លួនស្រឡាញ់ ។

PLATON

• ស្នេហាជាល្បែងសម្រាប់មនុស្សឆ្លាត មិនមែនជា ល្បែងសម្រាប់មនុស្សឃ្លានទេ ។

EURIPIDE

• ស្នេហាមានរសជាតិជាងអាពាហ៍ពិពាហ៍ ដូចគ្មានឹង អានប្រលោមលោក មានរសជាតិជាងអានប្រវត្តិសាស្ត្រ ។

CHAMFORT

• ស្នេហាគឺជារឿងប្រលោមនៃបេះដូង ឬថា : ស្នេហា

www.elibraryofcambodia.org

គឺជាប្រវត្តិសាស្ត្រនៃការត្រេកត្រអាល ។

BEAU MARCHAIS

● ស្នេហាស្មោះត្រង់ដូចជាស្រមោល អ្នកណាក៏គេនិយាយផល់រឿងស្មោះត្រង់នេះដែរ ប៉ុន្តែគេមិនសូវឃើញមនុស្សណាបានជួបប្រទះនឹងស្នេហាបរិសុទ្ធស្មោះត្រង់នេះឡើយ ។

ROCHE FOUCAULD

● ស្នេហាមានអានុភាពខ្លាំងជាងអាទិទេព វាអាចបញ្ចូលបេះដូងពីរឲ្យទៅតែមួយបាន ។

LA BOUISE

● ពីរប៉ុន្តែមួយ : ប្រុសនឹងស្រីបញ្ចូលគ្នាទៅជាព្រះឥន្ទ្រមួយអង្គនៅលើស្ថានសួគ៌ ។

VICTOR HUGO

● ស្នេហាគឺជាអ្វីដែលខ្ញុំមិនស្គាល់ មិនដឹងជាមកពីណា ហើយក៏មិនដឹងជាហេតុអ្វីបានជាវាបាត់ទៅវិញ ។

Mlle DE SEUDERY

● បុព្វហេតុនៃសេចក្ដីស្នេហាគឺជាអ្វីដែលខ្ញុំមិនយល់ ប៉ុន្តែ

www.elibraryofcambodia.org

អានុភាពរបស់វាយើងមិនអាចស្មានបានថាដាយ៉ាងណាទេ ។ ប្រការដែលខ្ញុំមិនយល់នោះ ពិតមែនតែវាមិនចំនួន ប៉ុន្តែវាអាចធ្វើឲ្យផែនដីញ័ររកក្រើកបាន ។

PASCAL

● ស្នេហាពិតមែនតែវាមិនសូវធំដុំប៉ុន្មាន ប៉ុន្តែវាជាបញ្ហាធ្ងន់ធ្ងរបំផុត នៅក្នុងជីវិតមនុស្សលោក ។

FRANCIS WEY

● ស្នេហាគឺជាជម្ងឺមួយយ៉ាង ដែលគ្មាននរណាគេព្យាបាលបាត់ លើកលែងតែមនុស្សណាដែលមានជម្ងឺនោះ ។

ALDOPHE RICARD

● ចំពោះសេចក្ដីស្នេហា ជ័យជំនះមានតែមួយទេគឺការគេចវេសខ្លួនចេញ ។

NAPOLEON BONAPARTE

● ស្នេហាគឺជាជម្ងឺមួយបែបមានបីរយៈគឺ ស្រេកឃ្លាន, សប្បាយ និងគុញខ្ទាំង ។

MEIL HAN

www.elibraryofcambodia.org

• អាពាហ៍ពិពាហ៍គឺជារណ្ដៅកប់ខ្មោចស្នេហា ។

CHAMFORT

• គេភ្លក់បានរសជាតិនៃសេចក្ដីស្នេហា នៅក្នុងការឈឺចាប់រាប់ពាន់ដងខ្លាំង ជាជាងនៅក្នុងការសប្បាយ ។

DULOS

• ស្នេហាមិនខុសគ្នានឹងជម្ងឺស្មងទេ កាន់តែខ្លាចវាខ្លាំងឡើង កាន់តែត្រូវវាឆ្លងទាញខ្លាំងឡើង ។

CHAMFORT

• ការបាត់មុខ (l'abscence) ក៏ជាឱសថមួយយ៉ាងល្អណាស់ដែរ ក្នុងកិច្ចការពារប្រឆាំងទល់នឹងសេចក្ដីស្នេហា ។

LAFONTAINE

• ឃ្លាំងទាំងអស់នៅក្នុងលោក មានតម្លៃមិនស្មើនឹងសុភមង្គលនៃសេចក្ដីស្នេហាឡើយ ។

CALDERON

• ក្នុងសង្គ្រាមស្នេហា ការរត់គេចខ្លួន គឺជាមធ្យោបាយដ៏ល្អមួយ ។

PETRARQUE

www.elibraryofcambodia.org

● ស្នេហាវាកើតឡើងហើយវាបាត់ទៅវិញ មិនដែលតាមបំណងរបស់មនុស្សឡើយ ។

Mme DE GIRARDIN

● ស្នេហាខ្លាំងជាងសេចក្តីស្លាប់ ។

VIRGIL

● ចំពោះសេចក្តីស្នេហា ស្អប់បានន័យថានៅស្រឡាញ់ នៅស្រឡាញ់ស្នេហាមួយដែលមិនបរិសុទ្ធ ។

STENDHAL

● ក្បែរសេចក្តីស្នេហា វាលំបាកជាងបង្កើតសេចក្តីស្នេហា ។

ABBE BLANCSARD

● ស្នេហាគឺជាគំនិតអត្តទត្ថភាពមួយយ៉ាងខ្លាំង : សូវយើងសុខចិត្តឃើញមនុស្ស ដែលយើងស្រឡាញ់អស់សង្ឃឹមនោះគេវេទនាជាជាងយើងឃើញគេស្លុកស្តុទ្ធរីករាយជាមួយនឹងប្រុសផ្សេង

ACHILLE POINCELOT

● តាមធម្មតា ស្នេហាគឺជាគំនិតអត្តទត្ថភាពមួយយ៉ាង

www.elibraryofcambodia.org

សាហាវ គេហ៊ានចំផ្ទាញដោយដៃគេនូវសុភមង្គលរបស់មនុស្ស ដែលគេស្រឡាញ់ ។

Mme DE STAËL

● ស្នេហាគឺជាទេវតាក្មេងមួយអង្គ ៖ តែកាលណាស្រឡាញ់ហើយ ទោះបីមនុស្សចេះដឹងយ៉ាងណាក៏ដោយ ក៏ក្លាយទៅជាកូនក្មេងដែរ ។

PROPERCE

● ស្នេហាគឺជាកំហុសរបស់សត្វលោក ។

RICHE PINE

● ស្នេហាស្មោះត្រង់មិនរើសគើងឋាន ៖ វណ្ណ ៖ ឬអាយុ គឺជាទេវតាសមភាព ។

LOPE DE VEGA

● ជីវិតមនុស្សដូចជាផ្កា ហើយស្នេហាដូចជាទឹកឃ្មុំ ។

VICTOR HUGO

● ស្នេហាអាចរស់នៅបាន អាស្រ័យដោយមានការឈឺចាប់ រស់នៅក្នុងសុភមង្គល ស្នេហានឹងត្រូវរលត់

www.elibraryofcambodia.org

ផ្គងបន្តិច ៗ ។

Mme GIRARDIN

● ស្នេហាគឺជាសួមយាចក វាចេះតែសុំមិនឈប់ឈរ ក្នុងពេលដែលគេបានឲ្យអស់ របស់ដែលគេមានទៅហើយ ។

P. ROCH PEDRE

● ស្នេហាបរិសុទ្ធ ធ្វើឲ្យមនុស្សស្រីទៅជាមានកិរិយានឹងនួនមិនផ្ទេកផ្ទាច ។

● ស្នេហាដោយគាប់ផ្តួន គឺជាប្រភេទស្នេហាមួយយ៉ាងពិបាកព្យាបាលបំផុត ។

LABRUYERE

● ស្នេហាវាស៊ីជម្រៅទៅក្នុងបេះដូងយើង ដោយសារការទម្លាប់ ហើយក៏ពីព្រោះតែការទម្លាប់នេះដែរ ទើបស្នេហាវារត់ចេញផុតពីបេះដូងយើងទៅ ។

SENEOUE

● គេមធ្យោបាយដើម្បីសងសឹកអ្នកណាមួយ បានន័យថាយើងនៅស្រឡាញ់អ្នកនោះ ។

A DOLPHE RICARD

www.elibraryofcambodia.org

● ស្នេហាគឺជាព្រលឹងនៃចក្រវាឡ  គឺជាប្រភពនៃសេចក្ដីសប្បាយ សេចក្ដីទុក្ខ ហើយក៏ជាល្បែងទៀតផង ។

DESTOUCHES

● តាមធម្មតា ស្នេហាគឺជាលទ្ធផលនៃអាពាហ៍ពិពាហ៍ ។

MOLIERE

– ស្នេហាគឺជាល្បែងលេងសប្បាយមួយយ៉ាង ចំណែកឯកិត្តិយសគឺជាភារ កិច្ច ។

P. CORNEILLE

● ស្នេហាគឺជាព្រះអាទិទេពតាចមួយ វាមិនអឲ្យស្រ័យដល់រូបអ្នកណាទាំងអស់ ។

P. CORNEILLE

● ស្នេហាធ្វើឲ្យពេលវេលាឆ្លងផុតរហ័សណាស់ ។

RENE YVES

● ស្នេហាវាមិនសូវខ្វាំងខ្វារទេ ចំពោះមនុស្សណាដែលមិនធ្លាប់បានស្រឡាញ់ ។

P. CORNEIL

www.elibraryofcambodia.org

● ស្នេហាមិនសុទ្ធតែនាំឲ្យយើងបានសេចក្ដីសុខ ឬ សេចក្ដីទុក្ខទាំងអស់ទេ ។

QUI NAULET

● ស្នេហាគឺជាកម្លាំងកសាង ឬជាកម្លាំងបំផ្លាញ យើងគប្បីណែនាំវាឲ្យបានស្រួល ទៅរកសេចក្ដីសុខ រកសុភមង្គល សេចក្ដីបរិសុទ្ធជាជាងយើងស្អប់ខ្ពើមវា រួញច្រានវាមិនទៅទេ ។

VERVARUS

● ស្នេហាខ្លាំងខ្លាណាស់ចំពោះមនុស្សណា ដែលមិនធ្លាប់ស្នេហា ។

DESTOUCHES

● ស្នេហាបរិសុទ្ធហើយស្អាត គេមិនបាច់និយាយពាក្យថាៈ ស្នេហាទេ គឺគេស្នេហាតែម្ដង ។

XOPHOLUS

● សេចក្ដីស្នេហានៅប្រទេសបារាំង គឺជារឿងកំប្លែង នៅប្រទេសអង់គ្លេស គឺជារឿងកំសត់សោកសៅនាដកភាព នៅប្រទេសអាល្លឺម៉ង់ គឺជារឿងសប្បាយ ។ ប៉ុន្តែចំពោះប្រទេស

www.elibraryofcambodia.org

អ៊ីតាលីវិញ ស្នេហាគឺជាទោងកាំនៃរឿងល្ខោនគ្រប់ប្រភេទ ។

MARGARET-B-

● មានស្នេហានៅក្នុងបេះដូង គឺមានស្ពាយឥវាន់មួយយ៉ាងធ្ងន់គាមខ្លួន ។

FRANÇOIS COPPEE

● ស្នេហាគឺជាអ្វី គឺជាការផ្លាស់ប្តូរគណ្ហាពីរមែនទេ ?

CHAMFORT

● ស្នេហា ស្នេហាដែលមនុស្សស្រឡាញ់ពេញចិត្តដូចគ្នានឹងភ្នំខ្ពស់មួយ គេច្រៀងលេងសប្បាយក្នុងពេល ដែលគេចំឡើងទៅដល់កំពូល ។ ប៉ុន្តែគេត្អូញត្អែរអ៊ូរទាំ ក្នុងពេលដែលគេចុះមកជើងភ្នំវិញ ។

GHAMFORT

● ស្នេហាគឺជាលោកថៅកែគំមួយ ។

MOLIERE

● ស្នេហាវាមានសប្បាយនឹងមានទុក្ខរបស់វា ។

LAFONTAINE

www.elibraryofcambodia.org

● គ្មានការក្លែងបន្លំណាលាក់បានយូរទេ ។ នៅកន្លែងណាមានស្នេហា យើងក៏មិនអាចធ្វើពើជាមិនស្គាល់វាដែរ ។

LA ROCHE FOUCAULD

● ក្នុងពេលធុញទ្រាន់ នឹងសេចក្ដីស្នេហាហើយយើងចូលចិត្តឲ្យគេក្បត់នឹងយើងណាស់ ដើម្បីដោះស្រាយកុំឲ្យគេថា យើងមនុស្សឥតធម៌មេត្តា ។

LA ROCHE FOUCAULD

● ស្នេហាបរិសុទ្ធមានតិចណាស់ វាតិចជាងការរាប់អានស្មោះត្រង់ទៅទៀត ។

LA ROCH

● ស្នេហារបស់យុវជន គឺជាស្នេហានៅនឹងភ្នែក វាមិនសូវទៅដល់អាពាហ៍ពិពាហ៍បានទេ ។

## បទវិចារណ៍

● ដំណក់ទឹកភ្នែកមុនដំបូងនៃមនុស្ស ដែលយើងស្រឡាញ់ គឺជាគ្រាប់ពេជ្រចរណៃ ដំណក់ទឹកភ្នែកទីពីរ គឺជាគ្រាប់ពេជ្រ ដំណក់ទី ៣ ដូចគ្នានឹងទី ៤ នឹងដំណក់ផងទៃ ។

ACHILLE PONCELOT

www.elibraryofcambodia.org

● ជោកប្រាសមានតម្លៃស្មើនឹងស្មោះត្រង់ បើកាលណា ហើយគេស្រវឹងនឹងស្នេហា ។

បទវិចារណ៍

● ក្នុងសង្គ្រាមក៏ដូចជានៅក្នុងរឿងស្នេហា តែកាលណា មានការចែចង់ឬជជែកគ្នាហើយ ដូចគ្នានឹងអ្នកឈ្នះសង្គ្រាមយក បន្ទាយបានពាក់កណ្ដាលឥចឹង ។

MARQUERITE DE VALOIS

● បុប្ផាមួយថែប ។ សុទ្ធតែមានភាសាស្នេហាផ្ទាល់ របស់គេ ។

បទវិចារណ៍

● ប្រមូលសត្រូវឲ្យកាន់តែច្រើនបានឈ្មោះថា ស្នេហា ។

HENRI DUVERNOIS

● សេចក្ដីស្នេហាលើកស្ទួយមនុស្ស ឲ្យផុតពីសភាព ធម្មតា ។

PASCAL

● ឱស្នេហាអើយ ! អ្នកឯងនេះហើយដែលបានធ្វើការរួច

www.elibraryofcambodia.org

គ្នាជាមួយនឹងគាវុធ ក្នុងកិច្ចប្រៈប្រយុទ្ធខាត់សាកលលោកទាំងមូល ។

CHARLES PERRIN

● មនុស្សយើង ផ្ទុំម្នាក់ច្រើនតែរត់មករកស្នេហាចាស់របស់ខ្លួនវិញ ។

ETIENNE

● សេចក្ដីស្លាប់បានធ្វើប្រការខ្លះ ដែលស្នេហាមិនអាចធ្វើបាន ។

A. DE MUSSET

● ខ្ញុំបានឆ្លងកាត់ពេលវេលាស្នេហាៈហើយឬនៅ ? ។

LA FONTAINE

● នៅក្នុងតណ្ហាទាំងអស់ កាមតណ្ហាខ្លាំងជាងគេពីព្រោះវាជាខួរក្បាល ហើយបេះដូងទៅជាដងខ្លួន ។

VOLTAIRE

● វត្ថុបំណងខ្ពង់ខ្ពស់នៃសេចក្ដីស្នេហាគឺ អាពាហ៍ពិពាហ៍ វត្ថុបំណងអាពាហ៍ពិពាហ៍គឺការបង្កើតកូន បង្កើតសុភមង្គលគ្រួសារ នឹងប្ដីប្រពន្ធជួយគ្នាទៅវិញទៅមក ដើម្បីធ្វើការ

www.elibraryofcambodia.org

ឲ្យមានប្រយោជន៍ដល់សង្គម ។

GERMAIN

● បើស្នេហាវាបែកបាក់អស់ទៅហើយ ត្រូវបោះបង់វាចោលទៅ ប្រការខ្លាំងខ្លង់ គឺ ត្រូវតែលើកលែងទោស ជាពិសេសទៅទៀត គឺ ត្រូវតែបំភ្លេចចោល នេះជាឱសថវិសេសមួយសម្រាប់ជម្ងឺបេះដូង របស់យើងទាំងអស់គ្នា ។

DERNIERE LETTRE de S

● ស្នេហាខ្លាំងពេក លោកទុកដូចជាមរណៈ ការប្រច័ណ្ឌខ្លាំងហើយសាហាវ លោកទុកដូចជាផ្នូរខ្មោច ។

CHANT DE SALOMON

● ចំណង់ស្នេហានាំឲ្យវិនាសមនុស្ស ដូចគ្នានឹងកណ្ដៀរកកេរសំលៀកបំពាក់ ។

ST CHRYSOSTOM

● គឺភ្នែករបស់ប្អូនឯងនេះហើយ ដែលបង្ហាញនូវពន្លឺនៃសេចក្ដីស្នេហា ។

H. COLERIDGE

www.elibraryofcambodia.org

● សេចក្ដីស្នេហា គឺជាវត្ថុដ៏ឆើតឆាយទាំងឡាយនៃធម្មជាតិ ។

NATKING COLE

● ស្នេហា គឺជាទណ្ឌកម្មមួយ ។ យើងទាំងអស់គ្នាសុទ្ធតែត្រូវទណ្ឌកម្មដោយរស់នៅម្នាក់ឯងមិនបាន ។

MAQUERITE YOURCENAR

● ស្នេហារបស់មនុស្សនៅក្មេង មិនមែនកើតឡើងពីបេះដូងពិតប្រាកដរបស់ខ្លួនទេ គឺកើតឡើងដោយសារភ្នែកគេ ។

WILLIAM SHAKESPEARE

● ស្នេហាជាសភាពទន់ភ្លន់ ។

SYMPOSIUM

● ដែលមានសប្បាយផ្អែមល្ហែម នឹងទុក្ខកំសត់ច្រើន គឺស្នេហា ។

BAILEY

● សេចក្ដីស្នេហាជាប្រេងសាំងនៃចិត្ត ឬជាព្រលឹងនៃចិត្ត។

SWEDEN BORG

www.elibraryofcambodia.org

● ក្នុងចំណោមព្រះអាទិទេពចាស់ទាំងឡាយ ស្នេហាជាព្រះអាទិទេពចាស់មួយមានតម្លៃ មានឥទ្ធិពលអាចផ្តល់គុណធម៌ ព្រហ្មចារីយ៍ សុភមង្គលដល់មនុស្សជាតិទាំងមនុស្សរស់នៅ និងទាំងមនុស្សស្លាប់ទៅ ។

PHAIDROS (symposium)

● ក្នុងជីវិតមនុស្ស មានការសោកសៅនាដកាពពីរយ៉ាងគឺ មិនព្រមលុះដោយបំណងនៃសេចក្តីប្រាថ្នារបស់ខ្លួន ។

GEORGE BERNARD SHAW

● ស្នេហានិងតណ្ហា វាជាមនុស្សជាតិរស់នៅក្នុងលោកយើងនេះ ។ បើគ្មានវាទេសាសនាប្រវត្តិសាស្ត្រចម្រៀង ប្រលោមលោកសិល្បៈ . . . ហាក់ដូចជាគ្មានប្រយោជន៍អ្វីសោះ ។

BALZAC

● ស្នេហាជាមហាសមុទ្រនៃការរំភើប ហើយវាទាក់ទងដល់ការចំណាយប្រាក់ផង ។

LORD DEWAR

● សេចក្តីស្នេហាគឺជាការទាស់ទែង រវាងកាយវិការដែល

www.elibraryofcambodia.org

កើតឡើងឯង ៗ នឹងការត្រិះរិះ ។

MAGNUS HIRSCHFELD

● និយាយអំពីវិធាននៃការស្នេហា គឺជាការប្រយុទ្ធប្រឆាំងចម្រុះគ្នាមួយ ។

SYMPOSIUM

● ព្រួញគ្រឹដជាព្រលឹងនៃសេចក្ដីស្នេហា ដែលមានការទាក់ទងផល់ចង្វាក់ភ្លេងនឹងការពិរោះ ។

SYMPOSIUM

● ស្នេហាជាសិល្បករមួយរូបយ៉ាងចំណាន វាអាចផ្ដេមនុស្សឲ្យទៅតាមចិត្តវាបាន ។

SYMPOSIUM

● ស្នេហាគឺជាការធ្វើត្រាប់តាមតៗ មក ។

## បទវិចារណ៍

● អ្នកដែលចេះកាន់យកនូវសេចក្ដីស្នេហា រួចហើយចេះដកថយចេះកាត់ចេញមកវិញ អ្នកនោះឯងគឺជាអ្នកជំនាញក្នុង

www.elibraryofcambodia.org

រឿងនេះ ។

SYMPOSIUM

● ស្នេហាគឺជាព្រលឹងនៃទឹកចិត្ត វាស្ថិតនៅចំកណ្តាលទ្វីប ហើយវាលុះដោយសេចក្តីស្លាប់ផង ។

SYMPOSIUM

● សេចក្តីស្នេហារបស់បុរសមានតិច តែញឹកញាប់គ្រប់ពេលវេលា ចំពោះស្ត្រីវិញមានសេចក្តីស្នេហាច្រើន ប៉ុន្តែមានតែម្តងពេល ។

BASTA

● សេចក្តីស្នេហាចំពោះបុរស មិនមែនជាមនោសញ្ចេតនាទេ ផ្ទុយទៅវិញវាជាគំនិតទទេ ។

*Mme* DE GIRARDIN

● ស្នេហាគឺជាផ្នែកខ្វាចក់ចិត្តនិងគំនិត ។

PLATO

● សេចក្តីស្នេហាគឺជាការយោគយល់សន្តោសចិត្តគ្នា . . .

**បទវិចារណ៍**

www.elibraryofcambodia.org

● សេចក្ដីស្នេហាគឺជាពេលអារណារៈ នៃអាកាហ៍ពិពាហ៍ ហើយអាពាហ៍ពិពាហ៍ គឺជាពេលអស្ដង្គតនៃការស្រឡាញ់ ។

DE-FINOD

● តាមការពិត សេចក្ដីស្នេហាមិនមែនប្រព្រឹត្តទៅដោយសុទ្ធតែបានសុខស្រួលឡើយ ។

SHAKESPEARE.'(M.N.D)

● ទោះបីយ៉ាងណាក៏ដោយ មនុស្សម្នាក់ៗ គេតែងតែនឹកត្រឡប់មករកស្នេហាដើម ឬស្នេហាទី ១ របស់គេវិញជាមិនខាន ។

ETIENNE (Jacoude)

www.elibraryofcambodia.org

## ប្រពន្ធ និងអាពាហ៍ពិពាហ៍

● នៅទីណាមានអាពាហ៍ពិពាហ៍ដោយគ្មានសេចក្ដីស្នេហារវាងប្រុសហើយនឹងស្រី នៅទីនោះក៏មានសេចក្ដីស្នេហាមិនបាច់រៀបការអីចឹងដែរ ។

FRANKLIN

● រៀបអាពាហ៍ពិពាហ៍ដោយបង្ខំចិត្ត គឺជាប្រលោមលោកមួយបែបដែលមានតួអង្គស្នេហា ត្រូវស្លាប់ម្នាក់ក្នុងជំពូកទី ១ នៃរឿង ។

បទវិចារណ៍

● ប្រុស ៗ បានជាគេរៀបការ ព្រោះគេអផ្សុកហើយធុញថប់ ចំណែកឯស្រី ៗ វិញ គេព្រមរៀបការពីព្រោះគេងឿងឆ្ងល់ ... ។ ដល់ទីបំផុត អ្នកទាំងពីរត្រូវខកចិត្ត ខកប្រាណយ៉ាងសោកស្ដាយ ។

WILDE

● អាពាហ៍ពិពាហ៍ គេប្រៀបបាននឹងការត្រូវឆ្នោតរង្វាន់ធំពីព្រោះប្រុស ៗ គេត្រូវបានសេរីភាពយ៉ាងរឹងប៉ឹងព្រមទាំងមានព្រំដែនថែមទៀតផង ចំណែកស្រី ៗ វិញ គឺគេបានទទួល

www.elibraryofcambodia.org

សុភមង្គល ។

Mme DE RIEUX

● ក៏ជាការល្អដែរ ការដែលមានស្នេហារួចហើយ ទើបបាត់បង់ជីវិតទៅវិញ ជាជាងការដែលមិនទាន់មានស្នេហាហើយត្រូវបាត់បង់ជីវិតទៅវិញ ។

TENNY SON

● ប្រច័ណ្ឌធ្លាក់វែងវៃបានសេចក្ដីថា ៖ ភ្លើងស្នាងក្នុងស្នេហា ចេះរក្សាសុភមង្គលគ្រួសារបើប្រច័ណ្ឌដោយល្មើសល្វង់បានសេចក្ដីថា បណ្ដេញបំបាត់នូវមនុស្សដែលខ្លួនស្រឡាញ់ ហើយនាំឲ្យគ្រួសារខ្លួនមានការលំបាកវេទនា ។

FRANÇOI MICHEL

● អាពាហ៍ពិពាហ៍មិនមែនគ្រាន់តែជាមធ្យោបាយដោះស្រាយកាមតណ្ហាប៉ុណ្ណោះនោះទេ វានៅមានតម្លៃខ្ពង់ខ្ពស់ជាងនេះទៅទៀត គឺធ្វើឲ្យព្រលឹងនៃមនុស្សទាំងពីរនាក់បានរីករាយផ្អែមល្ហែមថែមក្នុងជីវិត ។

www.elibraryofcambodia.org

● បើយើងចង់ទៅដល់អាពាហ៍ពិពាហ៍ យើងត្រូវមានវត្ថុអ្វីដើម្បីថែរក្សាវាសិន ។

J. C.

● អាពាហ៍ពិពាហ៍ដែលបានរៀបចំឡើង ឬរៀបឡើងសាជាថ្មីម្តងទៀត មិនមែនមកអំពីមនុស្សទេ គឺមកអំពីធម្មជាតិទេតើ ។

PIEXI

● និយាយរួមទៅ គេមិនសូវរៀបអាពាហ៍ពិពាហ៍នឹងសេចក្តីស្នេហាមុនដំបូងនោះទេ សេចក្តីស្នេហាមុនដំបូងច្រើនតែត្រូវខូចខាត ដោយមានអនុស្សាវរីយ៍យ៉ាងជូរចត់ ។ គេច្រើនកសាងគ្រួសារនៅក្នុងពេល ដែលគេធ្លាប់ជួបប្រទះនឹងសេចក្តីស្នេហារួចខ្លះកន្លងមកហើយ ។

PAUL STEPUS

● ប្រច័ណ្ឌបានសេចក្តីថា : យើងរស់នៅក្នុងសេចក្តីសង្ស័យ ។ វាអាចក្លាយទៅជាគ្រោះថ្នាក់ឬទៅជាការដាច់ស្រេចក្នុងចិត្តក្នុងករណីណា ដែលការសង្ស័យរបស់យើងនោះវាក្លាយទៅជាការពិតជាក់ស្តែង ។

LAROCHE FOUCAULD

www.elibraryofcambodia.org

● ដោយវិធីណាមួយនោះ ការប្រច័ណ្ឌវាជាការត្រឹមត្រូវមួយពីព្រោះវាការពារទ្រព្យសម្បត្តិ នឹងការពារចិត្តថ្លើមមនុស្សកុំឲ្យរវើរវាយ ។

LAROCHE FOUCAULD

● មានប្រការជាស្ពាពរពីរយ៉ាងនៅក្នុងសេចក្ដីស្នេហាគឺ : មួយកើតឡើងដោយសារការជួបប្រទះយ៉ាងថ្មីថ្មោង ដែលគួរឲ្យស្រឡាញ់ចំពោះមនុស្សដែលយើងស្រឡាញ់ពីគឺ មកអំពីគេយល់ថា: ស្ពាពរគឺ នៅលើកិត្តិយស ។

LAROCAH FOUCAULD

● ប្រច័ណ្ឌវាកើតឡើងអំពីសេចក្ដីស្នេហា ហើយវាស្លាប់ទៅវិញជាមួយនឹងសេចក្ដីស្នេហាដែរ ។

LAROCHE FOUCAULD

● នៅក្នុងរឿងប្រច័ណ្ឌ កត្តាដែលបណ្ដាលឡើងក៏ គ្មានអ្វីក្រៅអំពីសេចក្ដីស្នេហាទេ ។

LAROCHE FOUCAULD

● គេអត់អោនទោសឲ្យយើងនល់កម្រិតណា អនុលោម

www.elibraryofcambodia.org

ទៅតាមកម្រិតដែលគេស្រឡាញ់យើង ។

LAROHCE FOUCAULD

● អាពាហ៍ពិពាហ៍គេមិនដែលសន្ទនាគ្នាអំពីរឿងស្រឡាញ់ឬមិនស្រឡាញ់សាជាថ្មីឡើងវិញនោះទេ គេសន្ទនាគ្នាអំពីមធ្យោបាយធ្វើយ៉ាងណា ឲ្យបានអធិកអធម . . នោះទើបវាសមជាង។

PIERRE FORI

● គ្មានអ្វីធ្វើឲ្យឈឺចាប់ដល់សេចក្ដីស្នេហា ជាជាងការដែលយើងនិយាយប្រៀបធៀបប្ដី ឬប្រពន្ធយើងទៅនឹងអ្នកដទៃទេ។

EMILE STOCH

● ចំពោះរឿងអាពាហ៍ពិពាហ៍ តែខុសបន្តិចហើយគឺខុសមួយជីវិត ។

CH. WAGNER

● ពិចារណាដើម្បីចុះសន្យារៀបអាពាហ៍ពិពាហ៍ យើងមិនត្រូវពិចារណាដោយស្មារតីជាមនុស្សប្រុសម្នាក់ ស្រឡាញ់មនុស្សស្រីយ៉ាងទន់ខ្សោយនោះទេ គេត្រូវពិចារណាក្នុងស្មារតីខ្លួនយើងជាប្ដីនឹងជាឪពុកមួយរូបក្នុងអនាគត ។

ARTHUS

www.elibraryofcambodia.org

● មិនចេះប្រច័ណ្ឌបានសេចក្ដីថា ប្រទះត្រង់ណាប្រច័ណ្ឌត្រង់នោះមិនរវល់នឹងអ្វីទាំងអស់ បែបនេះមានគ្រោះថ្នាក់ច្រើនណាស់ ។

LITENA

● មុននឹងរៀបការ ការជ្រើសរើសប្ដីប្រពន្ធជាការសំខាន់ណាស់ ប៉ុន្តែដល់រៀបការរួចហើយ ប្រការសំខាន់បំផុតគឺត្រូវឲ្យចេះរាប់អានគ្នាដូចជាភ្ញៀវថ្លៃថ្នូរអីចឹង ។

Mme DAMROSCH

● អាពាហ៍ពិពាហ៍មានន័យសំខាន់ណាស់ ចំពោះជីវិតមនុស្ស វាសំខាន់ជាងការកើតនឹងការស្លាប់ទៅទៀត ។

DOROTHG-DIX

● ជាមុខការនឹងភារៈរបស់ស្ត្រី ៗ ត្រូវទទួលអាពាហ៍ពិពាហ៍ទាន់ខ្លួននៅវ័យក្មេង ឯបុរសវិញត្រូវនៅឲ្យចាស់តាមដែលគេទ្រាំបាន ។

GEOKGE BERNAR-DSHAW

● អ្នកខ្ចះបន់ព្រះជាម្ចាស់ឲ្យបានរៀបការជាមួយនឹង បុរស

www.elibraryofcambodia.org

ដែលខ្លួនស្រឡាញ់ ចំណែករូបខ្ញុំវិញ ខ្ញុំសូមបន់ព្រះជាម្ចាស់ឲ្យខ្ញុំស្រឡាញ់បុរសណា ដែលខ្ញុំរៀបការជាមួយនឹងគេទៅវិញ ។

ROSE·PASTOR

● រៀបការមួយដងក្នុងមួយជីវិត គឺជាករណីកិច្ច បើរៀបពីរដងគឺជាដំណើរលីលា បើរៀបបីដងគឺជាដំលីលាហើយឆ្កួតមួយជីវិតតែម្តង ។

DUTCH PROVERD

● អាពាហ៍ពិពាហ៍គឺ ជាចំណងជើងនៃរឿងមួយដែលស្ត្រីច្រើនតែយល់ព្រម ហើយបុរសច្រើនតែប្រកែក ។

WILDE

www.elibraryofcambodia.org

# ការស្រឡាញ់រាប់អាន

● គ្មានការស្រឡាញ់រាប់អានណាដែលមិនមានប្តូរយោបល់នឹងមនោសញ្ចេតនាទាំងគ្នានោះទេ ។

P. GILLET

● ការស្រឡាញ់រាប់អាន បើចង់ឲ្យមានប្រយោជន៍គួរប្រព្រឹត្តឲ្យបានថ្លៃថ្នូរ ។

St FRANÇOIS de SALES

● ខ្ញុំយល់ឃើញថា : ការស្រឡាញ់រាប់អានគ្នាគឺជាអំណោយមួយយ៉ាងល្អរបស់ទេវតារស់ផ្តល់ឲ្យខ្ញុំ ។

Mme SWETCHIRE

● ឧត្តមគតិនៃការស្រឡាញ់រាប់អាន យើងត្រូវស្មានថាវាតែ « មួយ » ? ប៉ុន្តែការពិតវា « ពីរ » ។

Mme SWETCHIRE.

● យ៉ាងម៉េច ? មិត្តគ្មានសេចក្តីស្នេហាហើយមិត្តអាចសន្និដ្ឋានថា មិត្តមានជីវិតឬ ?

A. DE MUSSET

www.elibraryofcambodia.org

● ការស្រឡាញ់រាប់អានវាចាំបាច់ដល់យុវជន វាធ្វើឲ្យយុវជនបានថ្លៃថ្នូរ នឹងដើម្បីជៀសវាងកាមតណ្ហាកុំឲ្យវាគ្រួសខាញ់បាន ។

● ការស្រឡាញ់រាប់អានវាចាំបាច់ដល់មនុស្សចាស់ ក្នុងករណីឈឺចាប់បានវាចបោសអង្អែល បានស្ដាប់ពាក្យលួងលោមនាំឲ្យមានសង្ឃឹម ។ ការស្រឡាញ់រាប់អានក៏មានប្រយោជន៍ដល់មនុស្សដែលមានវ័យកណ្ដាលច្រើនណាស់ដែរ វាជាការប្ដូរយោបល់នឹងប្ដូរសេចក្ដីប្រាថ្នា . . . ។

ARISTOTE

● ការស្រឡាញ់រាប់អានស្និទ្ធស្នាល គឺជាការលួងលោមបបោសអង្អែលមួយយ៉ាងធំនៅក្នុងលោក ។

MAUSORI

● ការណាមានទាក់ទងដល់សេចក្ដីរាប់អាន ស្និទ្ធស្នាលហើយស្មោះត្រង់ អានាគតរបស់វាគឺទៅដល់សេចក្ដីព្រមព្រៀងរៀបការ ។

A. BONNARD

www.elibraryofcambodia.org

● ការរាប់អានស្និទ្ធស្នាលគ្នា វាអាចជាវិធីមួយរបស់ទេវតាក្នុងការជួយសង្គ្រោះគ្នា ។

AD. TANGUREY

● នៅក្នុងលោកយើងនេះ គ្មានអ្នកណាពូកែគ្រប់មុខទេ ពិព្រោះហេតុនេះហើយបានជាត្រូវការសហប្រតិបត្តិការ ក្នុងករណីធ្វើការធំដុំ ។ មិត្តសំឡាញ់ស្និទ្ធស្នាលគឺជាសហការីមួយយ៉ាងសំខាន់ក្នុងការស្វែងរកជ័យជំនះ ។

MARCEL-ZONE

● វត្ថុបំណងនៃការស្រឡាញ់រាប់អានស្និទ្ធស្នាល គឺជាការកសាងជីវភាពឲ្យមានគ្នាដើម្បីទ្រាំទ្រសេចក្ដីលំបាកនៅក្នុងលោក ក្នុងវត្ថុបំណងធ្វើការឲ្យបានប្រយោជន៍ធំ ៗ ។

JEAN SCELLET

● សេចក្ដីស្រឡាញ់រាប់អានខ្ពង់ខ្ពស់ វាអាចជួយវិនិច្ឆ័យរឿងរ៉ាវខុសត្រូវរបស់យើង ជាជាងទ្រព្យសម្បត្តិ នឹងជាជាងកិត្តិយសអ្វីផ្សេង ៗ ទៅទៀត ។

St AMBROISE

www.elibraryofcambodia.org

● ដោយសារការរាប់អានស្និទ្ធស្នាល នេះហើយដែលមនុស្សបែកឆ្ងាយពីគ្នាហើយ បានរីករាយដូចជុំគ្នា មនុស្សមានជម្ងឺបានទទួលការថ្នាក់ថ្នម ហើយពិសេសជាងនេះទៅទៀតគឺមនុស្សស្លាប់ត្រូវបានរស់បន្តថែម ។

CICERON

● មកអំពីការរាប់អានស្និទ្ធស្នាលនេះហើយ ដែលនាំឲ្យមនុស្សមានការសប្បាយរីករាយ ។ បើគ្មានវាទេបណ្តាប្រការទាំងឡាយដែលនាំឲ្យមនុស្សចូលចិត្ត វានឹងក្លាយទៅជាការធុញទ្រាន់ ។ បើមានវាបណ្តាការលំបាកវេទនាទាំងអម្បាលមាណ នឹងត្រូវរលត់រលាយបាត់អស់គ្មានសល់ ។

St THOMAS D AQUIN

● សេចក្តីរាប់អានស្និទ្ធស្នាល គឺជាព្រលឹងមួយនៃមនុស្សដែលមានខ្លួនពីរ ។

PY THAGORE

● គ្មានអ្វីផុយស្រួយ ស្មើនឹងការស្រឡាញ់រាប់អានស្និទ្ធ-ស្នាលរបស់មនុស្សទេ ។ អស់ពេលយូរអង្វែងទើបកសាងបាន

www.elibraryofcambodia.org

ប៉ុន្តែវាអាចខូចបាត់បង់ភ្លាមក្នុង ១ វិនាទី ។

Bourdaloue

● ជាព្រាកដណាស់ នៅលើផែនដីយើងនេះ គ្មានវត្ថុអ្វីស្អាតបាត,ស្មោះត្រង់,បវរត្តភាព បរិសុទ្ធស្មើនឹងសេចក្តីរាប់អានស្និទ្ធស្នាលគ្នារស់ពេលយូរនោះទេ ។

C LHOTTE

● ស្រឡាញ់ពិតដឹក រាប់អានស្និទ្ធស្នាលយូរឆ្នាំជាមួយគ្នាហើយ យើងគប្បីកុំមានការសង្ស័យនាំគ្នា ។ ប៉ុន្តែត្រូវមានការមន្ទិលជានិច្ច ក្នុងករណីណាដែលមានរឿងលុយកាក់និងរឿងស្នេហាចូលលាយឡំជាមួយផង ។

CARANTES

● ការរាប់អានស្និទ្ធស្នាល គឺជាសេចក្តីស្នេហាមួយយ៉ាងខ្ពង់ខ្ពស់ស្មើគ្នានឹងសេចក្តីស្នេហា រវាងម្តាយនឹងកូនស្នេហាបងប្អូន ប៉ុន្តែវាត្រូវសាវភាពចំពោះស្នេហាកាមតណ្ហាបើកាលណាហើយកាមតណ្ហាវាចូលមកជ្រៀតជ្រែក ។

CALORUS AUGELUS

www.elibraryofcambodia.org

● ថ្នាំបំពុលពីរគ្រប់នៃសេចក្ដីស្រឡាញ់រាប់អានគ្នា គឺការបោកប្រាសនឹងស្មារតីអត្តទត្ថភាព ។

TRUC-VIET

● សត្រូវរបស់ទេវតា មិនអាចទៅជាមិត្តសំឡាញ់របស់មនុស្សបានទេ ។

St AMBROISN

● ស្រឡាញ់រាប់អាន គឺជាការចុះខសន្យាតាមវិធានធម្មជាតិ ដែលខួរក្បាលពីរមានសេរីភាព នឹងសន្យាគ្នាក្នុងកិច្ចស្នេហាជួយគ្នា ផាស់វៀនគ្នាទៅវិញទៅមក ។

A.H. PERREYVE

● មិត្តដើរផ្លូវជាមួយគ្នា គេមិនសូវជួបប្រទះនៅក្នុងពេលបុកនៃ្ទងស៊ីផឹកជប់លៀងទេ គេច្រើនជួបនៅក្នុងគុកច្រវាក់ទេតើ ។

HOANG LY TAO

● បើមានមនុស្សណាយល់ថា : មិត្ត ១០០ ឆ្នាំ(ប្រពន្ធប្ដី) ឬមិត្តខួរក្បាល គឺជាមនុស្សដែលមានចិត្តថ្មើមដូចយើងទាំងស្រុង មនុស្សបែបនេះរហូតដល់ពេលចូលរណ្ដៅទៅក៏នៅតែ

www.elibraryofcambodia.org

គ្មានប្រពន្ធនឹងគ្មានមិត្តភ័ក្រ្តដូចគេដែរ ។

J ISAAC

● ការស្រឡាញ់រាប់អានមែនទែន អាចមានតែរវាងមនុស្ស ត្រឹមត្រូវទេ ។ មូលដ្ឋានរបស់វាគឺសីលធម៌ហើយក៏ដោយសារតែសីលធម៌នោះឯងដែរ ដែលនាំឲ្យវាថ្កុំថ្កើង ។

ARISTOTE

● មិត្តសំឡាញ់ស្មោះត្រង់មែនទែន ទោះជានៅក្នុងករណីណាក៏ដោយក៏នៅតែស្រឡាញ់យើងជានិច្ច ។ មិត្តសំឡាញ់ចង់បានប្រយោជន៍ គឺមិនជួយយើងទេ ក្នុងករណីដែលយើងវេទនា ។

ECCL VI-8

● ខ្វះការថ្លឹងយោបល់ សេចក្ដីស្នេហារាប់អាននឹងត្រូវរលត់រលាយ ។

ARISTOTE

● បើចង់បែកមិត្រនិងបង្កើតសត្រូវ យើងត្រូវក្ដៅក្រហាយជេរប្រទេច ប្រកាន់ច្រើននឹងគំនិតអត្តទត្តភាព ។

FEURZINGER

www.elibraryofcambodia.org

● គ្រោះថ្នាក់ធំបំផុតនៅក្នុងជីវិត ដែលគេប្អូងសួងបញ្ជូនទៅឲ្យសត្រូវរបស់គេ គឺគេចង់ឲ្យសត្រូវរបស់គេស្រឡាញ់អ្នកណាមួយ ហើយកុំឲ្យអ្នកនោះស្រឡាញ់តបមកវិញ ។

LABOUISSE

● អាពាហ៍ពិពាហ៍មានលក្ខណៈ ចម្លងទម្លាប់អាក្រក់ពីមនុស្សប្រុសមកមនុស្សស្រី ជាជាងចម្លងទម្លាប់ល្អរបស់មនុស្សស្រីមកប្រុស ។

CH. FOURIER

www.elibraryofcambodia.org

ចូលរួចទៅហើយ កំពុងតែរកច្រកចេញមកវិញ ។

SOCRATE

● អាពាហ៍ពិពាហ៍មានប្រយោជន៍ដល់ស្រី តែប្រុស ៗ ទៅជាស្អប់វាវិញ ។ ការពិត អាពាហ៍ពិពាហ៍វាជាការអាម៉ាស ចំពោះស្ត្រីភេទ តែវាជាកិត្តិយសដល់បុរសភេទ ។

RICHEPIN

● ត្រូវបន់ម្តងមុននឹងចេញទៅសមរភូមិ ។ ត្រូវបន់ពីរដងមុននឹងចុះតប៉ាល់ឆ្លងមហាសាគរ តែត្រូវបន់ដល់ទៅបីដងមុននឹងសម្រេចចិត្តរៀបការជាមួយអ្នកណាម្នាក់ ។

ភាសិត

● បើចង់ឲ្យអាពាហ៍ពិពាហ៍បានសម្រេចសុភមង្គលប្រុសត្រូវបានធ្វើថ្លង់ ស្រីត្រូវបានធ្វើខ្វាក់ ។

ALPHONSE D'ARAGON

● ចំណងអាពាហ៍ពិពាហ៍រឹតតឹងខ្លាំងពេក វានាំឲ្យមនុស្សគ្រាំគ្រាច្រើនជាជាងនាំឲ្យមនុស្សស្រឡាញ់គ្នា ។

PH de VARENNE

www.elibraryofcambodia.org

● យ៉ាងណាដែលហៅថាល្អ? គឺត្រូវបានគេស្រឡាញ់ ... ចំណែកឯលោក Voltaire វិញត្រឡប់ជាថា «គឺងក់ញីចំពោះគីង្គក់ឈ្មោលរបស់វា» ។

● ពិបាកនឹងស្រឡាញ់ជាលើកទី ២ ណាស់ មនុស្សដែលខ្លួនអស់ស្រឡាញ់ទៅហើយ ។

LA ROCHEFOU CAULD

● រៀបការដោយគ្មានស្នេហា មិនខុសណានឹងមានប្រាក់ហើយចាយមិនបាន ។

RIVAROL

● លក្ខណៈដែលនាំឲ្យប្រុសស្រឡាញ់ស្រី មុនដំបូងបង្អស់ គឺស្រីនោះចូលចិត្តប្រុសនោះមុនសិន ។ ចំណែកឯស្រីវិញគឺផ្សេង : ស្ត្រីស្រឡាញ់ប្រុសម្នាក់កាលណាមនុស្សនៅជុំវិញខ្លួនគេយល់ព្រមនឹងលើកសរសើរមនុស្សប្រុសនោះ ។

CH. ROMAINVILLE

● រកមធ្យោបាយដើម្បីសងសឹកបានន័យថានៅស្រឡាញ់នៅឡើយ ។

ADOLPHE RICARD

www.elibraryofcambodia.org

● ស្រឡាញ់មានន័យថាៈ បានចុះខសន្យានឹងសេចក្ដីទុក្ខ ។

Mme COHIN

● ស្រឡាញ់នឹងឈឺចាប់ ។ យើងពិបាកសំគាល់បានណាស់ ពីព្រោះអាពីរនេះវាកើតឡើងជាមួយនឹងទឹកភ្នែកទាំងអស់គ្នា ។

REGNIER DE TOURBET

● ស្នេហាគ្មានរើសអាយុះ ផ្ទុយទៅវិញ បើកាមតណ្ហាវាថយចុះហើយ សេចក្ដីស្នេហាក៏ថយចុះហើយចាកចេញផុត ដូចមេអំបៅចេញពីសំបុកដែរ ។

EMERSON

● មិនសុទ្ធតែគេស្រឡាញ់យើង ហើយយើងត្រូវតែបានស្រឡាញ់គេវិញនោះទេ ។ មិនបានសន្យានឹងអ្នកណាមួយបានសេចក្ដីថា ខ្លួនគ្មានចំណោលនឹងត្រូវសងគេវិញ ។

Mme de SARTORY

● មានតែមនុស្សដែលយើងស្រឡាញ់ខ្លាំងទេដែលអាចធ្វើឲ្យយើងឈឺចាប់យ៉ាងខ្លាំង ។

J. CHARDONNES

www.elibraryofcambodia.org

● ស្រឡាញ់ឈឺចាប់ពីព្រោះតែស្រឡាញ់ទៅចុះ រាជាជាង រស់នៅគ្មានការស្រឡាញ់ ។

Mme DE LESPINASSE

● ស្រមោលនៃមនុស្សដែលយើងស្រឡាញ់ មិនខុស ណានឹងស្រមោលរបស់យើងទេ វាចេះតែតាមពីក្រោយខ្លួន យើងជានិច្ច ។

SAINT PROSPER

● បើចង់ឲ្យបានសេចក្តីស្នេហាបង្កើតបានសុភមង្គល ប្រការ សំខាន់បំផុត គឺអ្នកដែលយើងស្រឡាញ់នោះ គឺជាមនុស្សដែល ស្គាល់ចិត្តថ្លើមរបស់យើងបំផុត ។

A. MAUROIS

● ស្រឡាញ់គឺគោរព បើមិនគោរពគឺមិនស្រឡាញ់ ។

STAHL

● បានគេស្រឡាញ់ខ្លួន គឺជាសុភមង្គលរបស់មនុស្ស យើង ស្រឡាញ់គេហើយមិនខ្វល់នឹងគេស្រឡាញ់យើងវិញ នេះគឺ ជាសុភមង្គលនៃទេវតា ។

CHARLES POUGEN

www.elibraryofcambodia.org

● បើចង់ដឹងថា : យ៉ាងណាដែលហៅថាសុភមង្គល យើងត្រូវចេះរស់នៅដើម្បីអ្នកដទៃ គឺថាត្រូវចេះស្រឡាញ់ ។

GODWIN

● ចាប់ផ្តើមស្រឡាញ់ គឺចាប់ផ្តើមរស់ ។

នាងកញ្ញា de SEUDER

● ធ្វើខ្ញុំបំរើស្នេហា គឺជាខ្ញុំបំរើយ៉ាងថោកទាប, ប្រុសណា សុំសេចក្តីស្នេហាពីគេដែលមិនស្រឡាញ់ខ្លួន គឺជាមនុស្សប្រុសល្ងង់បំផុត ។

DANIEL STERN

● មនុស្សប្រុសច្រើនស្រឡាញ់ស្រីខ្លះ ដែលគេមិនសូវគោរពកោតខ្លាច ផ្ទុយទៅវិញ មនុស្សស្រីច្រើនស្រឡាញ់ប្រុសខ្លះដែលគេគោរពកោតខ្លាច ។

SANIAL DUBAY

● គ្មានទាសភាពណាគួរឲ្យអាណិតអាសូរជាងទាសភាពស្នេហាទេ ។

Mlle de LESPINASSE

www.elibraryofcambodia.org

● ប្រការដែលគួរឲ្យស្តាយខាងស្នេហាគឺ ៖ កាលនៅពីក្មេង ការពិសោធន៍វានៅខ្វះ ដល់ទៅចាស់ត្រឡប់ជាមានពិសោធន៍ច្រើន ។

ROCH PECHE

● យកប្រាក់មកលទើបដឹងថា ស្នេហាស្មោះត្រង់ឬយ៉ាងណា ។

ROCHE BRUNE

● នៅឆ្ងាយពីគ្នាយូរថ្ងៃពេក ក៏ដូចជានៅជាមួយគ្នាមមេះមមោះច្រើនពេក គឺជារណ្តៅកប់ខ្មោចស្នេហា ។

BOISSY

● កាលណាតែគេស្រឡាញ់ គេច្រើនតែសង្ស័យនូវប្រការណាដែលគេមានជំនឿបំផុត ។

LA ROCHE FAUCAULD

● ទៅនិយាយរួចសេចក្តីស្នេហារបស់ខ្លួនបែបយ៉ាងណា ៗ បានសេចក្តីថា ខ្លួនមិនទាន់ស្រឡាញ់ខ្លាំងនៅឡើយទេ ។

PETRARQUE

www.elibraryofcambodia.org

● មនុស្សដែលយើងស្រឡាញ់ជាងគេ គឺជាមនុស្សដែលយើងមិនសូវនិយាយដល់ចំពោះមុខអ្នកដទៃជាងគេ ។

BEAUCHENE

● ការស្និទ្ធស្នាលហួសហេតុ ហើយមម៉េះមម៉ោះច្រើន ងាយនាំឲ្យអន្តរាយសេចក្ដីស្នេហាជាងការរាប់អានគ្នា ។

ROCHE PEDRE

● គ្មានអ្វីគួរឲ្យអនិច្ចា នឹងគួរឲ្យអស់សំណើចជាងឃើញលោកព្រិទ្ធាចារ្យទសនវិទូ ម្នាក់ការប្រពន្ធទេ ។

J. JOUBERT

● ក្នុងមធ្យោបាយ ចំបាត់សេចក្ដីស្នេហាទាំងអស់គ្មានមធ្យោបាយណាសក្តិសិទ្ធជាងធ្វើឲ្យស្នេហាបានឆ្អែតឆ្អន់ទេ ។

MARIVAUX

● មនុស្សណាដែលកំពុងតែស្រឡាញ់គេ ហើយស្រាប់តែទៅជាស្អប់ អ្នកនោះឯងនៅតែជាខ្ញុំបំរើនៃសេចក្ដីស្នេហាដដែល ។

OVIDE

www.elibraryofcambodia.org

● កំពុងតែស្រឡាញ់ខ្លាំងហើយស្រាប់តែទៅជាស្អប់បានន័យ

ថា : នៅស្រឡាញ់នឹងលួចស្រឡាញ់ថែមទៀត ។

Mlle de SCUDERY

● ទៅណាមកណា បើមិនចេះធ្វើឲ្យគេស្រឡាញ់ខ្លួនទេ

សុំកុំតែធ្វើឲ្យគេស្អប់ ។

អនាមិក

● សងសឹកនឹងមនុស្សម្នាក់ដែលយើងស្រឡាញ់ ពីព្រោះ

មនុស្សនោះក្បត់យើង បានសេចក្តីថាយើងនៅស្រឡាញ់

មនុស្សនោះ ។

ADOLPHE RIÇARD

● ស្លាប់ឲ្យមនុស្សដែលយើងស្រឡាញ់វា ងាយជាងរស់នៅ

ជាមួយនឹងមនុស្សដែលយើងស្រឡាញ់ ។

BYRON

● អ្នកណារកបានមិត្រក្នុងចំណោមមនុស្ស ដែលខ្លួន

ស្រឡាញ់គឺថា រកបានសុភមង្គលទាំងស្រុង ។

X . . .

www.elibraryofcambodia.org

● ការខ្វះសេចក្ដីគួរសមឬខ្វះរបៀបសុជីវធម៌ ជាប្រការមួយសម្លាប់សេចក្ដីស្នេហា ៖ បើនឹងថាដូច្នោះហើយ ចុះហេតុអ្វីបានជាយើងចេះរបៀបគួរសមជាមួយនឹងភ្ញៀវ នឹងអ្នកដទៃ ជាជាងមនុស្សដែលយើងស្និទ្ធស្នាលនៅក្នុងគ្រួសារយើងទៅវិញ ។

X . . .

● តែឃ្លានគឺស៊ីឆ្ងាញ់ តែស្រឡាញ់ហើយ អ្នកណាក៏ល្អដែរ ។

## ភាសិត

● ស្រីទាំងអស់សុទ្ធតែល្អ ពីព្រោះបានប្រុសស្រឡាញ់ បើយើងមិនស្រឡាញ់មានគេស្រឡាញ់ ។

X . . .

● សេចក្ដីស្នេហារបស់យើងទាំងស្រុង ដាក់ជំនឿទៅលើមនុស្សដែលយើងស្រឡាញ់ បានន័យថា ៖ សេចក្ដីស្នេហារបស់យើងឡើងកំរិតខ្ពស់ហួសប្រមាណ ។

ABEL, SONNARD

● ស្នេហាស្មោះត្រង់បរិសុទ្ធ គឺជាផ្លូវនាំយើងទៅផល់

www.elibraryofcambodia.org

កន្លែងដែលមានជំនឿ ។

EMERSON

● បើមិនស្គាល់ការលោភលោសទេ គឺគេមិនធ្លាប់ស្រឡាញ់ ។

បទវិចារណ៍

# ស្រឡាញ់

● មនុស្សចេះស្រឡាញ់ បានសេចក្ដីថា : មនុស្ស មិនត្រូវរិះគន់ទិទៀន ឬសំគាល់ប្រការល្អិតល្អោច នៃមនុស្ស ដែលយើងស្រឡាញ់ ។

P. BOURGET

● ក្នុងពេលដែលគេកំពុងតែស្រឡាញ់គ្នា គេមិនសូវគិត ដល់រឿងដែលគេនឹងលែងគ្នាទេ ។

ANDRIEUX

● ត្រូវជ្រើសរើសឲ្យហើយសឹមដាក់ចិត្តថាស្រឡាញ់ ។

SENEGUE

● បើបរិសុទ្ធខ្លាំង គឺ ស្រឡាញ់ក៏ខ្លាំងដែរ ។

Mme de STAEL

www.elibraryofcambodia.org

● មនុស្សកើតឡើង គឺសម្រាប់តែសេចក្ដីស្នេហា សម្រាប់តែការស្រឡាញ់ មែនឬទេ ? ។ ដូច្នោះមែន ! ទោះបីមនុស្សខំលាក់លៀមគ្រប់មធ្យោបាយយ៉ាងណាក៏ដោយ ក៏គ្មានអ្នកណាមួយដែលគេចរួចពីការស្រឡាញ់នោះដែរ គេស្រឡាញ់ជានិច្ច ។ សូម្បីតែអ្នកបួសនៅក្នុងព្រៃជ្រៅ ឬរូងភ្នំឆ្ងាយដាច់ស្រយាលពីសង្គមមនុស្ស ក៏ជាអ្នកដែលមានការអោយតម្លៃនូវសេចក្ដីស្នេហាជាងអ្នកណាទាំងអស់ដែរ ។

BROW NING

● មនុស្សនៅក្មេងមិនទាន់ស្គាល់តម្លៃនៃសេចក្ដីស្នេហានឹងការស្រឡាញ់យ៉ាងណាទេ ! ស្នេហាតែកាមគុណមួយមុខគឺជាសំណល់នៃសេចក្ដីស្នេហាបរិសុទ្ធ ។

DANTE

● ឋានសួគ៌ មិនបើកទ្វារឲ្យពួកមនុស្សដែលមានសេចក្ដីស្នេហា ឬការស្រឡាញ់ពាសវាលឆ្វេចឆ្វាចចូលទៅបានទេ ។

PROFESSEUR PAUL

● តែចាប់ផ្ដើមស្រឡាញ់ ហើយគឺគេនឹកគិតទៅដល់

www.elibraryofcambodia.org

សេចក្ដីស្លាប់ ។ មនុស្សតែចាប់ផ្ដើមស្រឡាញ់ហើយ គំគេមិនខ្លាចអត់ឃ្លានទេ មិនខ្លាចក្រទេ មិនខ្លាចលំបាកវេទនាទេ។ បើគេរស់ដើម្បីស្នេហា គឺគេមិនខ្លាចស្លាប់ពីព្រោះស្នេហាឡើយ ។

MARSE CHOISY

● បើគេយល់បានច្បាស់នូវមុខងារពិត នៃសេចក្ដីស្នេហា គឺថា : ការប្រែប្រួលទាំងអស់ប្បាលមាណនៅក្នុងលោកដែលមានកន្លងមក ជីវិតដែលមានកន្លងមកមិនបានន័យថាផាសម្រុទ្រទុក្ខទេ ។

BO YIN-RA

● ស្អប់ខ្ទើម គឺជាកូនភ្លោះ នឹងសេចក្ដីស្នេហាមិនបរិសុទ្ធ ។

PROFESSEUR PAUL

● ស្រឡាញ់មិនមែនរកប្រយោជន៍ឲ្យខ្លួនទេ គឺរកកុសលទេតើ ។

SERTILLANGES

● ស្រឡាញ់គឺស្លាប់ក្នុងចិត្តអស់ខ្លះហើយ ។

XUAN DIEU

www.elibraryofcambodia.org

● មានតែការស្រឡាញ់ ហើយទប់បានប៉ុណ្ណោះទេ ដែលជាស្នេហាខ្ពង់ខ្ពស់ សមទៅតាមមនុស្សមានឧត្តមគតិ ។

NHATQUANG

● កាន់តែស្រឡាញ់ខ្លាំង បើឃ្លាតឆ្ងាយកាន់តែសប្បាយខ្លាំង ។

LAFONTAINE

● ស្នេហាច្រើនបេះដូងរីកធំ ។

JOUBER

● ស្នេហាឈ្នះគ្រប់កិច្ចការអ្វីទាំងអស់ ។

VIRCIL

● ការពិតនៃសេចក្ដីស្នេហា គឺជាវិធីបន្តមនុស្សឲ្យរស់នៅក្នុងលោក ។ ប៉ុន្តែមានមនុស្សខ្លះយល់ច្រឡំថាវត្ថុបំណងនៃជីវិតមនុស្ស ទៅជាយកវាមកបំរើសេចក្ដីសប្បាយ . . . ម្ល៉ោះហើយបានជាទទួលគ្រោះថ្នាក់ទទួលផលវិបាកអាក្រក់ទៅវិញ ។

CHAR LES CHRISTINIAN

● ស្នេហាគឺជាកម្លាំងមនោសញ្ចេតនាខ្លាំងបំផុត វាអាច

www.elibraryofcambodia.org

ទាញមនុស្សបានគ្រប់គ្នា វាអាចធ្វើឲ្យមនុស្សចិត្តស្រាលផ្តួតបាន ដូចគ្នានឹងសត្វមមៀចចូលភ្លើង ។

J.^QUES PLUS

● ស្នេហាគឺជាការត្រេកត្រអាលមួយថ្ងៃ ចំណែកឯអាពាហ៍ពិពាហ៍ គឺជាសុភមង្គលមួយជីវិត ។

DELAVIGNE

● ព្រះអាទិទេពស្រឡាញ់គ្នាមិនសូវរៀបការទេ ។

P. CORNEILLE

● គ្មានអ្វីឈ្មះស្នេហាទេ ស្នេហានៅពីលើសត្វលោកទាំងអស់ ។

LAFONTAINE

● ស្រឡាញ់គ្នាខ្លាំង ផ្លូវឆ្ងាយក្លាយទៅជាជិត ស្អប់គ្នាផ្លូវជិតក្លាយទៅជាឆ្ងាយ ។

## បទវិចារណ៍

● តម្លៃនៃកាមតណ្ហា វាផ្តកទៅលើតម្លៃនៃមនុស្ស

www.elibraryofcambodia.org

ទាំងមូល ។

GUSTAVE THIBON

● ស្នេហាមិនដែលគ្មានវត្ថុចំណាងទេ ហើយក៏មិនចេះតែ

ផ្តល់ផលអាក្រក់មកឲ្យយើងដែរ ។

MICHEL

● ខ្ញុំស្រឡាញ់បង ពីព្រោះបងគឺជាបង ។

MONTAIGNE

● សាសនានឹងមិត្រភ័ក្រ គឺបបួលគ្នាចំពេញកុសល ។

MANCIUS

● ការស្រឡាញ់ជាមិត្រភ័ក្រ គឺជាខ្សែចងភ្ជាប់គ្រប់កិច្ច

ការទាំងអស់ ។

St AUGUSTIN

●. កាលណាមានការទាក់ទងគ្នាស្និទ្ធស្នាល ហើយស្មោះ

ត្រង់វាអាចនាំទៅដល់អនាគតមួយ គឺការសន្យារៀបអាពាហ៍–

ពិពាហ៍ជាមួយគ្នា ។

A BONNARD

www.elibraryofcambodia.org

● គ្មានសេចក្ដីស្នេហាណា ដែលមិនគិតដល់រឿងកាមគុននោះទេ ពីព្រោះស្នេហាវាត្រាយផ្លូវឲ្យកាមតណ្ហា ។

KERGALARD

● មានមនុស្សគុនណាដែលមិនហើរ ! មានស្រីគុនណាដែលមិនលះប្រច័ណ្ឌ លើកលែងតែគេមិនស្រឡាញ់ ។

បរិវិចារណ៍

● តែខ្ញុំស្រឡាញ់គឺមានតម្លៃ ចំណែកឯវត្ថុដទៃ គឺគ្មានតម្លៃទាល់តែសោះ ។

A. DE MUSSET

● ស្នេហា បើគេពិនិត្យឲ្យជ្រៅជ្រះទៅគឺ : ដូចជាវាំនាំសេចក្ដីទុក្ខមកឲ្យយើងច្រើនជាងសេចក្ដីសុខ នឹងការរាប់អានគ្នា ។

LA ROCHE FOUCAULD

● បើមានគេសួរថា : តើស្នេហាគុនណាដែលល្អជាងគេនៅក្នុងលោកយើងនេះ ? ។ ខ្ញុំសុំឆ្លើយថា : មានតែស្នេហារវាងកូននឹងម្ដាយ និងស្នេហារាប់អានគ្នាប៉ុណ្ណោះ

www.elibraryofcambodia.org

www.elibraryofcambodia.org